នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារនៃការដាក់ឯកសារ

សំណុំរឿងលេខ	៖	០០៣/០៧-០៩-២០០៩-អវតក/កសចស/អបជ ៣៥
ដាក់ជូន	៖	អង្គបុរេជំនុំជម្រះ
ថ្ងៃដាក់	៖	ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩
ភាគីអ្នកដាក់	៖	សហព្រះរាជអាជ្ញាអន្តរជាតិ
ភាសាដើម	៖	អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Jul-2019, 11:04
CMS/CFO: Sann Rada

ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖ **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ៖ សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីដែលបានពិនិត្យ៖

ហត្ថលេខា៖

ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (D267)

អ្នកដាក់ឯកសារ៖
សហព្រះរាជអាជ្ញាអន្តរជាតិ
លោក Nicholas KOUMJIAN

ចម្លងជូន៖
សហព្រះរាជអាជ្ញាជាតិ
លោកស្រី ជា លាង

អ្នកទទួលឯកសារ៖
អង្គបុរេជំនុំជម្រះ
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

សហមេធាវីការពារក្តី មាស មុត
លោក អាង ឧត្តម
លោក Michael KARNAVAS

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី
ទាំងអស់ក្នុងសំណុំរឿង០០៣

I. សេចក្តីផ្តើម

1. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានចេញដីកាដំណោះស្រាយមួយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ដោយបានចោទប្រកាន់ មាស មុត ចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងការរំលោភទៅលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងឱ្យបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[1]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញដីកាដំណោះស្រាយមួយ ("ដីកាសម្រេចលើកលែងចោទប្រកាន់") ដោយបានលើកលែងការចោទប្រកាន់ប្រឆាំង មាស មុត ដោយសំអាងថា "អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ មាស មុត"[2]។ មាស មុត បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿង ទៅជំនុំជម្រះ ("បណ្តឹងឧទ្ធរណ៍")[3]។

2. នៅក្នុងបណ្តឹងឧទ្ធរណ៍នោះ មាស មុត ទទួលស្គាល់ថា ឧក្រិដ្ឋកម្មដែលខ្លួនត្រូវបានចោទប្រកាន់ គឺ "ជាការព្រួយបារម្ភបំផុតចំពោះសហគមន៍អន្តរជាតិ"[4]។ គាត់មិនជំទាស់នឹងសំអាងហេតុ ឬសំអាងច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនោះ ឬសំអាងហេតុរបស់ ស.ច.ស.អ ដែលថា "អ.វ.ត.ក មានយុត្តាធិការបុគ្គលលើ មាស មុត ដោយសារ គាត់ជាសមាជិកម្នាក់នៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ"[5] ប៉ុន្តែ គាត់លើកទឡ្ហីករណ៍ថា គាត់មិនគួរត្រូវបញ្ជូនទៅជំនុំជម្រះទេ។ បណ្តឹងឧទ្ធរណ៍របស់ មាស មុត គួរត្រូវបានបដិសេធផ្អែកលើហេតុផលខាងក្រោម។

---

[1] ឯកសារ **D267** ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ទំព័រ ២៥៦-២៦៥។

[2] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាលើកលែងចោទប្រកាន់") កថាខណ្ឌ ៤២៧-៤៣០។

[3] ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០ ("បណ្តឹងឧទ្ធរណ៍")។

[4] ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៤។

[5] ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៥៦។

II. ប្រវត្តិនីតិវិធី និងច្បាប់ជាធរមាន

3. ស.ព.អ សូមយោងទៅប្រវត្តិនីតិវិធីដែលមាននៅក្នុងឧបសម្ព័ន្ធ I ដែលភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់គាត់[6]។ ចំណែក ច្បាប់ជាធរមានមានចែងនៅក្នុងវាក្យខណ្ឌពាក់ព័ន្ធខាងក្រោម។

4. នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ ("អ.ប.ជ") បានសម្រេចបង្កើនពេលវេលា និងចំនួនទំព័រឯកសារ ដែលកំណត់សម្រាប់ចម្លើយតបរបស់គូភាគីទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ ដោយបានណែនាំពួកគេឱ្យដាក់ចម្លើយតបរបស់ខ្លួននៅក្នុងរយៈពេល ៤៥ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងនៃសំណៅបកប្រែនៃបណ្តឹងឧទ្ធរណ៍ដែលពួកគេត្រូវធ្វើការឆ្លើយតប[7]។ សំណៅបកប្រែជាភាសាខ្មែរនៃបណ្តឹងឧទ្ធរណ៍របស់ មាស មុត ត្រូវបានជូនដំណឹងនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩[8] ធ្វើឱ្យចម្លើយតបនេះផុតកំណត់នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩។ ការឆ្លើយតបចំពោះចម្លើយតបរបស់ភាគីមានរយៈពេលចំនួន២៥ថ្ងៃចាប់ពីពេលជូនដំណឹងអំពីឯកសារបកប្រែចម្លើយតបទាំងអស់[9]។

III. សេចក្តីសន្និដ្ឋាន

ក. សំណើសុំសវនាការសាធារណៈ

---

6 ឯកសារ **D266/2.2** ឧបសម្ព័ន្ធ I: ប្រវត្តនីតិវិធី ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩។

7 ឯកសារ **D266/4** & ឯកសារ **D267/6** សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់ចម្លើយតប និងការឆ្លើយតបនានា ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយសំណុំរឿង ០០៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ("សេចក្តីសម្រេចបន្ថែមពេលវេលា") ទំព័រ ៥។

8 *សូមមើល* អ៊ីមែលស្តីពីការជូនដំណឹងពីមន្ត្រីគ្រប់គ្រងសំណុំរឿង ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ នៅម៉ោង ២.០៩ រសៀល។

9 ឯកសារ **D266/4** & ឯកសារ **D267/6** សេចក្តីសម្រេចបន្ថែមពេលវេលា ទំព័រ ៥។

5. មាស មុត ស្នើឱ្យ អ.ប.ជ ស្តាប់ភាគីនៅក្នុងសវនាការជាសាធារណៈអនុលោមតាមវិធានផ្ទៃក្នុង[10] ៧៧(៦)[11]។ ស.ព.អ គាំទ្រសំណើរបស់ មាស មុត និងសូមធ្វើការសន្និដ្ឋានថា សវនាការជាសាធារណៈគឺជាផលប្រយោជន៍យុត្តិធម៌ និងធ្វើឱ្យមានការយល់ដឹងជាសាធារណៈអំពីកិច្ចការរបស់ អ.វ.ត.ក។ ស.ព.អ សូមធ្វើការសន្និដ្ឋានថា គ្មានការពិចារណាលើភាពសម្ងាត់ដែលតម្រូវឱ្យមានសវនាការក្នុងបន្ទប់សម្ងាត់ឡើយ។ ខ្លឹមសារដីកាសម្រេចចោទប្រកាន់ និងដីកាសម្រេចលើកលែងចោទប្រកាន់ សុទ្ធតែមានការដឹងជាសាធារណៈរួចស្រេចហើយ[12] ដូច្នេះមិនមានហានិភ័យរំលោភលើវិធានការការពារ ឬដីការក្សាការសម្ងាត់ឡើយ។

ខ. ការទទួលយកបាន

6. ស.ព.អ ទទួលស្គាល់កាតព្វកិច្ចរបស់ អ.ប.ជ ក្នុងការកំណត់យុត្តាធិការរបស់ខ្លួន។ ក្នុងកាលៈទេសៈទាំងនេះ ស.ព.អ មិនជំទាស់ ការធ្វើសារណារបស់ មាស មុត លើផលវិបាក នៃការចេញដីកាសម្រេចលើកលែងចោទប្រកាន់ និង ដីកាសម្រេចចោទប្រកាន់របស់ ស.ច.ស ដំណាលគ្នា ដូចគ្នានឹងការណ៍ដែល ស.ព.អ អនុវត្តនៅក្នុងបរិបទនៃបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹង ដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ ដែរ[13]។ អាស្រ័យហេតុនេះ ស.ព.អ សូមធ្វើការឆ្លើយតបដូចខាងក្រោម។

7. ទោះជាយ៉ាងណាក៏ដោយ ផ្ទុយទៅនឹងការអះអាងរបស់ មាស មុត[14] ស.ព.អ សូមធ្វើការសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានអនុលោមតាមវិធាន៧៤(៣)(ក) និង វិធាន២១

---

10 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មទី ៩) ដែលបានធ្វើវិសោធនកម្មកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង") ឬ "វិធាន")។

11 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២។

12 អត្ថបទសាធារណៈនៃដីកាដំណោះស្រាយនេះ មានការកោសលុបតិចតួចបំផុតចំពោះព័ត៌មានបញ្ជាក់ពីអត្តសញ្ញាណរបស់សាក្សីមួយចំនួនតូច និងអាសយដ្ឋានរបស់ មាស មុត។ ពុំមានការកោសលុបណាធ្វើឱ្យប៉ះពាល់ដល់ខ្លឹមសារ ឬការសម្រេចសេចក្តីនៃដីកាដំណោះស្រាយនេះទេ។ ស្រដៀងគ្នានេះដែរ អត្ថបទសាធារណៈនៃដីកាលើកលែងចោទប្រកាន់មានការកោសលុបដោយកាន់តែតិចបំផុតពីចំនួនឈ្មោះសាក្សី។

13 **ឯកសារ D266/2** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ") ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ១៩១-១៩៨។

14 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១-៤។

ជាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបញ្ជាក់លើយុត្តាធិការរបស់ អ.វ.ត.ក ទេ។ អ.ប.ជ យល់ថា វិធាន៧៤(៣)(ក) គ្រោមលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច និង ដីកាទាំងឡាយ ដែលបញ្ជាក់ពីយុត្តាធិការ "បុគ្គល ពេលវេលា និង រឿងក្តី"[15] របស់ អ.វ.ត.ក។ ទោះជាយ៉ាងណាក៏ដោយ បណ្តឹងឧទ្ធរណ៍របស់ មាស មុត មិនមែនជាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ[16]។ គាត់មិនបានចោទប្រកាន់អំពីកំហុសអង្គច្បាប់ដែលបដិសេធដីកាសម្រេចចោទប្រកាន់ ទាំងស្រុង ឬដោយផ្នែក ឬកំហុសអង្គហេតុ ដែលបណ្តាលឲ្យមានភាពមិនយុត្តិធម៌ ឬគាត់មិនអះអាងថា ស.ច.ស.អ បានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន ដែលសន្និដ្ឋានថា មាស មុត ស្ថិតក្នុងចំណោមជន ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ហេតុដូច្នេះ ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[17]។ មាស មុត មិនបានលើកសំណូមពរដែលតម្រូវឲ្យ អ.ប.ជ កែប្រែ ឬបដិសេធដីកាសម្រេចចោទប្រកាន់ឡើយ[18]។

8. ផ្ទុយទៅវិញ "បណ្តឹងឧទ្ធរណ៍"របស់ មាស មុត ស្ថិតនៅក្រៅក្របខ័ណ្ឌនៃដីកាសម្រេចចោទប្រកាន់ និងពាក់ព័ន្ធនឹងផលវិបាកនានានៃការចេញដីកាសម្រេចចោទប្រកាន់ស្របជាមួយនឹងដីកាសម្រេចលើកលែងចោទប្រកាន់។ នេះគឺជាប្រធានបទដែលបានដោះស្រាយរួចហើយដោយ ស.ច.ស.អ

---

15 *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២-**ឯកសារ D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ") កថាខណ្ឌ ៤៧។

16 *សូមមើល* ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១។

17 សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ២១ (សេចក្តីសម្រេចជាឯកច្ឆន្ទ) ដែលបានដកស្រង់សេចក្តីពេញលេញនីក្នុងឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៧។ *សូមមើល ផងដែរ* ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧, ៦៤ [ទទួលស្គាល់ចំណុចនេះថាជា បទដ្ឋាននៃការពិនិត្យឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍ស្តីពីសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ]។ សំណុំរឿង ០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១២-១១៣ និងសេចក្តីដកស្រង់នៅក្នុងសាលដីកានោះ។ រឿងក្តី *Brđanin* សំណុំរឿងលេខ IT-99-36-A អង្គជំនុំជម្រះតុលាការកំពូល សាលដីកា ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៧-១៦។

18 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ ទំព័រ ៤៦។

នៅក្នុងដីកាសម្រេចចោទប្រកាន់[19] ហើយដែល មាស មុត ទទួលស្គាល់ថា វាអាស្រ័យលើ អ.ប.ជ[20] តែប៉ុណ្ណោះ។ មាស មុត ស្នើសុំឱ្យមានការបកស្រាយទូលាយជាងនេះទៅលើវិធាន ៧៤(៣)(ក) តាមរយៈការអនុវត្តវិធាន២១[21] ប៉ុន្តែគ្មានអ្វីគួរឱ្យសង្ស័យទេថា បណ្តឹងឧទ្ធរណ៍នេះ មិនអាចទទួលយកបានអនុលោមតាមវិធាន៧៤(៣)(ក) ដូច្នេះ មិនចាំបាច់មានជំនួយលើការបកស្រាយលើវិធាន ២១ ឡើយ។

គ. អង្គសេចក្តី

១. បញ្ហាបឋមពាក់ព័ន្ធនឹងឋានៈនៃដីកាសម្រេចលើកលែងចោទប្រកាន់

9. ក្នុងបណ្តឹងឧទ្ធរណ៍ទាំងមូល មាស មុត អះអាងថា “នៅពេលគ្មានសំឡេងភាគច្រើនលើសលប់ដែលថា ស.ច.ស.ជ បានប្រព្រឹត្តកំហុស ឬការរំលោភបំពាន ដែលជាការកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិរបស់គាត់” ដីកាសម្រេចលើកលែងចោទប្រកាន់មិនអាចត្រូវបានច្រានចោល និងត្រូវមានអានុភាពលុបលើដីកាសម្រេចលើកលែងចោទប្រកាន់[22]។ ហេតុដូច្នេះ មាស មុត ប៉ុនប៉ងជាច្រើនលើកក្នុងការបង្ហាញថា ស.ច.ស.ជ មិនប្រព្រឹត្តកំហុស និងលើកទឡ្ហីករណ៍ថា ដីកាសម្រេចចោទប្រកាន់មិនអាចស្ថិតក្រោមការទទួលពិនិត្យរបស់ អ.ជ.ស.ជ ឡើយ ដោយហេតុថា

---

[19] ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៩, ៥៧៩។ នៅត្រង់កថាខណ្ឌ ១៩ ស.ច.ស.អ យោងទៅឯកសារ **D262.2** ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ ១៣-១៦។ *ជាពិសេស សូមមើល* កថាខណ្ឌ ១៦ [“យើងយល់ឃើញថា ដំណាក់កាលស៊ើបសួរចប់នៅដំណាក់កាលចុងក្រោយបំផុត គឺនៅពេលដែល អ.ប.ជ ចេញសាលដីកាប្រឆាំងនឹងដីកាដំណោះស្រាយ។ ប្រសិនបើ អ.ប.ជ មិនមានសំឡេងភាគច្រើនគាំទ្រដីកាដំណោះស្រាយមួយ ក្នុងចំណោមដីកាដំណោះស្រាយទាំងពីរទេនោះ ដីកាដំណោះស្រាយទាំងពីរត្រូវតម្កល់ទុកជាបានការ តាមការអនុវត្តវិធាន ៧៧(១៣) ប៉ុន្តែ តាមការយល់ឃើញរបស់យើង មិនមាន*កិច្ចស៊ើបសួរក្នុងន័យចង្អៀត*ថែមទៀត ដែលអាចបន្តទៅមុខទេ ។ យ៉ាងណាក៏ដោយ ដំណោះស្រាយសម្រាប់សេណារីយ៉ូបែបនេះ គឺស្ថិតនៅក្នុងយុត្តាធិការទាំងស្រុងរបស់ អ.ប.ជ”។ (មានបញ្ជាក់បន្ថែម]។

[20] ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣២។

[21] ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣។

[22] ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ ទំព័រ ១ កថាខណ្ឌ ៦៦។ *សូមមើល ផងដែរ* ទំព័រ ២ កថាខណ្ឌ ២, ៩, ៤៥, ៤៩, ៦២-៦៦។

ស.ច.ស.ជ និង ស.ច.ស.អ សុទ្ធតែផ្តល់សំអាងហេតុរបស់ខ្លួននៅក្នុងដីកាដំណោះស្រាយ ដែលមានឋានៈស្មើគ្នា[23]។

10. ស.ព.អ យល់ស្របជាមួយ មាស មុត[24]ថា ស.ច.ស មានឋានៈស្មើគ្នា និងមានសិទ្ធិអំណាចឯករាជ្យ ក្រោមច្បាប់ អ.វ.ត.ក[25] ប៉ុន្តែ ស.ព.អ មិនយល់ស្របថា ប្រសិនបើ ស.ច.ស មានគំនិតផ្សេងគ្នានៅក្នុងដីកាដំណោះស្រាយទៅលើថាតើជនត្រូវចោទស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដំណើរការនីតិវិធីត្រូវជាប់គាំង និងឈប់ដំណើរការទាំងស្រុង។ ទីមួយ ដូចដែល ស.ព.អ បានលើកឡើងយ៉ាងច្រើននៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់[26] ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ មានកំហុសអង្គហេតុ និងច្បាប់ជាច្រើន ដែលធ្វើឲ្យបាត់បង់ការអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ក្នុងការសម្រេចថា មាស មុត មិនមែនជាជនដែល "ទទួលខុសត្រូវខ្ពស់បំផុត"ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ ទីពីរ ដូចដែលពិភាក្សាខាងក្រោម បើទោះជា អ.ប.ជ គួរតែយល់ឃើញថា ដីកាដំណោះស្រាយទាំងពីរគឺជាការអនុវត្តឆន្ទានុសិទ្ធិដោយត្រឹមត្រូវរបស់ ស.ច.ស ម្នាក់ៗ ឬប្រសិនបើ អ.ប.ជ មិនអាចរកបានសំឡេងភាគច្រើនចាំបាច់សម្រាប់ឲ្យមានការសម្រេចមួយ ចេតនាច្បាស់លាស់នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក[27] និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[28] គឺថា ដីកាសម្រេចចោទប្រកាន់នឹងត្រូវបន្តទៅដំណាក់កាលជំនុំជម្រះ។

11. ផ្អែកលើកម្រិតនៃសេចក្តីលម្អិតដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ដើម្បីចៀសវាងភាពច្រំដែល ស.ព.អ លើកទឡ្ហីករណ៍ របស់ មាស មុត

---

23 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ ទំព័រ ១ កថាខណ្ឌ ៣៧, ៥២-៦១, ៦៥។

24 *សូមមើល* ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ ទំព័រ ១ កថាខណ្ឌ ៣៤, ៣៧, ៤៥, ៦០, ៦៦។

25 *សូមមើល ឧទាហរណ៍* កិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក មាត្រា ៥(១)-(៣)។ ច្បាប់បង្កើត អ.វ.ត.ក មាត្រា ១២, ២៧*ថ្មី*។

26 **ឯកសារ D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ។

27 កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០០៣ លេខ 2329 UNTS 117 ("កិច្ចព្រមព្រៀង អ.វ.ត.ក")។

28 ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីនូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដោយមានការដាក់បញ្ចូលនូវវិសោធនកម្ម ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ("ច្បាប់បង្កើត អ.វ.ត.ក")។

ដោយសង្ខេប មកដោះស្រាយ។ ផ្ទុយទៅនឹងការអះអាងរបស់ មាស មុត[29] ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានផ្ដល់សំអាងហេតុដែលជាការតម្រូវទៅលើអង្គហេតុទាំងអស់ ដែល ស.ច.ស ទទួលពិនិត្យចាត់ការក្នុងសំណុំរឿង០០៣ឡើយ[30]។ ដូចដែលបានលើកឡើងលម្អិតនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ[31] ដីកាសម្រេចលើកលែងចោទប្រកាន់មិនមានលើកឡើងពីសំអាងហេតុ ឬសំអាងច្បាប់ណាមួយអំពី (i) មន្ទីរសន្តិសុខទឹកសាប (ii) ការដ្ឋានតំបន់រាម និងសហករណ៍ (ដែលរួមមាន បិតត្រាង កង កេង និង កន្លែងសម្លាប់ ពាក់ព័ន្ធ) (iii) ការបោសសម្អាតកងពល១១៧ និង កម្មាភិបាលតំបន់៥០៥ ក្នុងខេត្តក្រចេះ (iv) ការបោសសម្អាតកងពលដទៃទៀត (ក្រៅពីកងពល ១៦៤) ក្នុងរួមមាន អ្នកដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១[32] និង (v) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (និងរំលោភផ្លូវភេទក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ)[33]។

12. លើសពីនេះទៀត ទោះបីជា មាស មុត មានការជំទាស់ក៏ដោយ[34] ក៏ការពឹងផ្អែករបស់ ដីកាសម្រេចលើកលែងចោទប្រកាន់ តែទៅលើភស្តុតាងដែលបានដាក់ក្នុងសំណុំរឿង ០០៣ នៅត្រឹម

---

29 ឯកសារ **D267/4** បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២១, ៥៤។

30 *សូមមើល* ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៣, ៦៣។ .

31 ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៦៣-៨២, ១២៧-១៣៣, ១៥៨។

32 *ផ្ទុយពី* ឯកសារ **D267/4** បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៤.ង, ៥៤ *ដែលយោងទៅ* ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២២៩-២៥៨។ ស.ច.ស បានពិចារណាអំពីការបោសសម្អាតសមាជិកនៃកងពលមជ្ឈិម កងវរៈសេនាធំឯករាជ្យ និងអគ្គសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជាទាំងអស់។ ដោយសារតែដីកាលើកលែងចោទប្រកាន់ធ្វើការពិចារណាដោយមានកម្រិតទាក់ទងនឹងតួនាទីរបស់ មាស មុត នៅក្នុងការបោសសម្អាតទាំងនេះ ជាពិសេស កងពលលេខ ១៦៤ ដីកានេះខកខានពុំបានលើកឡើងពីការបោសសម្អាតកងពលលេខ ១១៧, ៣១០, ៥០២ ឬពុំបានទទួលស្គាល់ថាជាជនរងគ្រោះទេ ចំពោះកម្មាភិបាលកងទ័ពណាដែលស្ថិតនៅក្រៅកងពលលេខ ១៦៤ ដែលគេបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។ *សូមមើល* ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៦៨ ៧៩-៨១, ១៣២-១៣៣, ១៦៩-១៧០។

33 *ផ្ទុយពី* ឯកសារ **D267/4** បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៤.ជ, ៥៤ *ដែលយោងទៅ* ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ៨២, ៩២-៩៣។ ស.ច.ស បានពិចារណាអំពីការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងតំបន់កំពង់សោម។ ការសំអាងនៅក្នុងដីកាលើកលែងចោទប្រកាន់ ទៅលើគោលនយោបាយរៀបការដោយបង្ខំរបស់ ប.ក.ក នៅទូទាំងប្រទេស គឺពុំមានបំណងពិចារណាលើភស្តុតាងពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ (ឬការរំលោភសេពសន្ថវៈនៅក្នុងចំណោមការរៀបការដោយបង្ខំ) នៅតំបន់កំពង់សោម ឬពាក់ព័ន្ធនឹង មាស មុត ឬការចូលរួមពាក់ព័ន្ធរបស់កងពលលេខ ១៦៤ នៅក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក នៅទីនោះទេ។ *សូមមើល* ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៦៩, ៧១-៧២, ១៣១, ១៥៨។

34 ឯកសារ **D267/4** បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៣, ៥៣។

ថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០១១ នៅពេលដែល ស.ច.ស.ជ យូ ប៊ុនឡេង និង ស.ច.ស.អ Siegfried Blunk យល់ស្រប ក្នុងការបញ្ចប់កិច្ចស៊ើបសួរដោយចេញការជូនដំណឹង អនុលោមតាមវិធាន ៦៦ (១)[35] គឺជាកំហុសអង្គច្បាប់ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សំអាងហេតុរបស់ ស.ច.ស.ជ ដែលថា មាស មុត មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ។ គិតត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១១ ស.ច.ស មិនបានរួចផុតពីកាតព្វកិច្ចក្នុងការអនុវត្តកិច្ចស៊ើបសួរពេញលេញមួយ ហើយ ទោះបីជា ការលើកឡើងជាវិជ្ជមានរបស់ មាស មុត លើចំណុចនេះក៏ដោយ[36] ក៏ពុំមានលក្ខណៈពេញលេញដែរ[37]។ បើទោះជា ស.ច.ស មានឯករាជ្យភាពនៅក្នុងការបំពេញកិច្ចស៊ើបសួរ ប៉ុន្តែ ដូច ដែល មាស មុត បានរម្លឹក[38] ឯករាជ្យភាពនេះមិនរួមទាំងឆន្ទានុសិទ្ធិដោយសេរីក្នុងការកំណត់ថា ពេលណាកិច្ចស៊ើបសួរត្រូវបានបញ្ចប់តាមច្បាប់នោះទេ។ ស.ច.ស មានកាតព្វកិច្ចក្នុងការបំពេញកិច្ចស៊ើបសួរពេញលេញ ពិតប្រាកដ មិនលម្អៀង និងមានប្រសិទ្ធភាព ទៅលើអង្គហេតុទាំងអស់ដែល ស.ច.ស បានទទួលចាត់ការ ហើយសេរីភាពដែលទទួលបានក្នុងការកំណត់អំពីរបៀបថាតើខ្លួនអនុវត្តយ៉ាងដូច្នេះនោះ មិនអនុញ្ញាតឲ្យគាត់បដិសេធមិនស៊ើបអង្កេតបានទេ[39]។

13. ជាមួយភាពប្រទាំងប្រទើសមួយចំនួន មាស មុត អះអាងថា ទោះបីជា ស.ច.ស.ជ ថ្លែងម្តងហើយម្តងទៀតថា ខ្លួនមិនបានពិចារណាលើភស្តុតាងដែលដាក់នៅក្នុងសំណុំរឿងក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[40]ក៏ដោយ ក៏ ស.ច.ស.ជ "នៅតែចូលរួមពាក់ព័ន្ធនៅក្នុងកិច្ចស៊ើបសួរទាំងមូល ហើយបានពិចារណាលើសម្ភារឯកសារនៅក្នុងសំណុំរឿងនៅមុនពេលធ្វើសេចក្តីព្រាងដីកាសម្រេចលើកលែងចោទប្រកាន់"[41]ដែរ។ ទោះជាយ៉ាងនេះក៏ដោយ ឯកសារដែល មាស មុត លើកឡើង[42] គឺជាការដាក់ឯកសារនីតិវិធី ភាគច្រើនទាក់ទិននឹងផលវិបាកនៃសេចក្តីសម្រេចរបស់ ស.ច.ស ក្នុងការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ និងការសម្រេច

---

35 ឯកសារ **D266** ដីកាលើកលែងចោទប្រកាន់ កថាខណ្ឌ ២, ១៨, ៣៩, ៤១-៤២។

36 **ឯកសារ D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៤-១៦។

37 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៤៩-៥៧។

38 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥២។

39 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៣, ៤៣-៤៨។

40 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២, ១៨, ៣៩, ៤១-៤២។

41 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៣។

42 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ លេខយោងជើងទំព័រ ២៤៩។

ដែលមានសុពលភាព[43]របស់ ស.ច.ស.អ.ប Laurent Kasper-Ansermet នៅខែធ្នូ ឆ្នាំ ២០១១ ថា កិច្ចស៊ើបសួរនេះគួរបើកឡើងវិញ[44]។ ស.ច.ស.ជ បានយោងដល់ភស្តុតាងឯកសារដែលមានចំនួនតិចតួចដែលចុះកាលបរិច្ឆេទក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[45] ប៉ុន្តែភស្តុតាងឯកសារ

---

43 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៣៦-៤២។

44 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ លេខយោងជើងទំព័រ ៧ (*ដែលសំអាងលើ*ឯកសារ **D257/1/8** សេចក្តីសម្រេចលើពាក្យសុំរបស់ មាស មុត សុំឱ្យធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយ ដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ [ដែលសំអាងតែនៅត្រង់ផ្នែកខ្លះនៃសេចក្តីសម្រេចដែលពាក់ព័ន្ធនឹងឯកសារទាំងឡាយ ដែលបានដាក់ទៅក្នុងសំណុំរឿង ០០៣ មុននឹងការបិទបញ្ចប់កិច្ចស៊ើបសួរ]) លេខយោងជើងទំព័រ ២៥ (*ដែលសំអាងទៅលើ*ឯកសារ **D11/3/3** ដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ នៅ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ បន្ថែមលើឯកសារពីរ មុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។ ឯកសារ **D11/4/3** ដីកាសម្រេចស្តីអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈ្មោះ Timothy Scott Deeds ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១) លេខយោងជើងទំព័រ ២៧-៤០, ៤២, ៤៦-៤៨, ៥១ (*ដែលសំអាងទៅលើ*លទ្ធផលផ្នែកនីតិវិធីនៃសេចក្តីសម្រេចបញ្ចប់កិច្ចស៊ើបសួររបស់ ស.ច.ស កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១១) លេខយោងជើងទំព័រ ៥៤ (ដែលសំអាងទៅលើសំណុំរឿង ០០៤/០២-ឯកសារ **D208/1/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ចុះថ្ងៃទី២២ ខែ មករា ឆ្នាំ២០១៥) លេខយោងជើងទំព័រ ៥៧ (*ដែលសំអាងទៅលើ* ឯកសារ **D87/2/1.9/1** ដីកាសម្រេចលើសំណើរបស់ មាស មុត សុំលទ្ធផលការងាររបស់អ្នកស៊ើបអង្កេត ក.ស.ច.ស នៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥) លេខយោងជើងទំព័រ ១១០០-១១០៣, ១១០៥ (*ដែលសំអាងទៅលើ*យុត្តិសាស្ត្រជាច្រើនរបស់ អ.វ.ត.ក ពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារបានមកដោយការធ្វើទារុណកម្ម)។

45 *សូមមើល* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ លេខយោងជើងទំព័រ ៩៤២ (*ដែលសំអាងទៅលើ* ឯកសារ **D22.1.14** សារទូរលេខអន្តរជាតិ *ការចាប់ខ្លួនបុគ្គលិកជនជាតិអាមេរិកកាំង* ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៨ ដែលភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងឯកសារ **D22** សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់ ស.ព.អ ក្នុងសំណុំរឿងលេខ ០០៣ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ដែលត្រូវបាន ស.ច.ស Blunk និង យូ ប៊ុនឡេង ចំនួនពីរដង ហើយដែលត្រូវបាន ស.ច.ស.អ Kasper-Ansermet ដាក់ចូលទៅក្នុងសំណុំរឿងកាលពីថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១២។ ដីកាលើកលែងចោទប្រកាន់ក៏សំអាងទៅលើភ័ស្តុតាងនៅក្នុងប្រតិចារឹកនៃសំណុំរឿង ០០១ ចំនួនបី ដែលបានដាក់ទៅក្នុងសំណុំរឿង ០០៣ បន្ទាប់ពីចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១៖ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ លេខយោងជើងទំព័រ ២៣៥-២៣៦, ៣៣០, ៣៣២, ៨៥០ *ដែលសំអាងទៅលើ*សំណុំរឿង ០០១-ឯកសារ **E1/19.1** ប្រតិចារឹក ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ (សេចក្តីយោងនៅក្នុងសំណុំរឿង ០០៣ ក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១៖ ឯកសារ **D54/6.1.9** និង ឯកសារ **D98/3.1.86**)។ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ លេខយោងជើងទំព័រ ៥១៥ *ដែលសំអាងទៅលើ*សំណុំរឿង ០០១-ឯកសារប្រតិចារឹកសវនាការ **E1/20.1** ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ (សេចក្តីយោងនៅក្នុងសំណុំរឿង ០០៣ ក្រោយថ្ងៃទី២៩

ទាំងនេះមិនគ្រប់គ្រាន់សម្រាប់គាំទ្រការអះអាងដែលថា ស.ច.ស.ជ "នៅតែចូលរួមពាក់ព័ន្ធ" ជាមួយភស្តុតាង ដោយហេតុថា ភស្តុតាងឯកសារជិត ២៥០០ ក្នុងនោះ រួមមានកំណត់ហេតុស្តាប់ចម្លើយថ្មីប្រមាណ៩៤៥ ត្រូវបានបន្ថែមទៅក្នុងសំណុំរឿងនៅចន្លោះពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដល់ពេលដែលកិច្ចស៊ើបសួរត្រូវបានបញ្ចប់ក្រោយមកដោយ ស.ច.ស.អ.ប Laurent Kasper-Ansermet និង ស.ច.ស.អ Mark Harmon និង Michael Bohlander[46]។

14. ក្រៅពីការផ្តល់ភស្តុតាងស្ទើរតែទាំងអស់បានមកពីមូលដ្ឋានឧក្រិដ្ឋកម្ម និងជនសង្ស័យ ចំពោះទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ឧក្រិដ្ឋ ដែលត្រូវបានលុបចោលទាំងស្រុងពីដីកាសម្រេចលើកលែងចោទប្រកាន់[47] ភស្តុតាងប្រមូលក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ មានតួនាទីជាមូលដ្ឋានក្នុងសំអាងហេតុដែលមានកំហុស ដែលមានឥទ្ធិពលលើការកំណត់យុត្តាធិការបុគ្គលរបស់ ស.ច.ស.ជ។ ឧទាហរណ៍នៃកំហុសទាំងនេះរួមមាន (i) ការកំណត់ចំនួន និងប្រភេទជនរងគ្រោះដែល មាស មុត ទទួលខុសត្រូវនៅមន្ទីរសន្តិសុខវត្តឥន្ទញាណ ការដ្ឋានស្ទឹងហាវ និង ជនបរទេស ដែលត្រូវបានសម្លាប់នៅសមុទ្រ នៅលើកោះ នៅតំបន់កំពង់សោម និងនៅមន្ទី ស-២១ ដែលរួមមានអ្នកដែលត្រូវបានចាប់ខ្លួនដោយកងកម្លាំងកងពលលេខ១របស់ភូមិភាគបស្ចិម[48] (ii) ការវាយតម្លៃលើការចូលរួមរបស់ មាស មុត នៅក្នុងការអនុវត្តគោលនយោបាយចំពោះខ្មាំង និងការធ្វើឱ្យទៅជាទាសករតាមរយៈការចុះទៅមើលមន្ទីរសន្តិសុខកំពង់សោម និងការដ្ឋាន និង ការកំណត់មុខសញ្ញាខ្មាំង[49] (iii) ការបន្តតួនាទីរបស់ មាស មុត ជាលេខាកងពល១៦៤ ដោយការគ្រប់គ្រងពេញលេញទៅលើយោធា និងស៊ីវិលក្នុងតំបន់កំពង់សោម រហូតដល់ខែមករា ឆ្នាំ១៩៧៩[50] និង (iv) តំណែងរបស់ មាសមុត ជាសមាជិកនៃសេនាធិការចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៥ និងអនុប្រធានសេនាធិការចាប់ពីចុងឆ្នាំ

ខែមេសា ឆ្នាំ២០១១៖ ឯកសារ **D54/6.1.10** និង ឯកសារ **D98/1.2.1**)។ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ លេខយោងជើងទំព័រ ២៩១-២៩២, ៣១២-៣១៤, ៣១៧-៣១៨, ៣២១ (*ដែលសំអាងទៅលើ*សំណុំរឿង ០០១-ឯកសារប្រតិចារិកសវនាការ **E1/29.1** ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ (សេចក្តីយោងនៅក្នុងសំណុំរឿង ០០៣ ក្រោយពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១៖ **ឯកសារ D55/8.1.4** និង ឯកសារ **D98/3.1.90**)។

46 សម្រាប់សេចក្តីលម្អិតបន្ថែម *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៥៥-៥៦។

47 *សូមមើល* ខាងលើ កថាខណ្ឌ ១១។

48 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៥៥-១៧០។

49 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១០៣-១០៧, ១២១-១៣៤។

50 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៣៧-១៤១។

១៩៧៨[51]។ ជាពិសេស សម្រាប់ការវាយតម្លៃលើយុត្តាធិការបុគ្គល[52] ភស្តុតាងក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ បានផ្តល់ជាភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់ថា មាស មុត បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម[53]។

15. ដីកាលើកលែងចោទប្រកាន់ក៏មានកំហុសអង្គហេតុដ៏ធំក្នុងការខកខានមិនបានផ្តល់សំអាងហេតុ និងសំអាងច្បាប់លើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត និងការទទួលខុសត្រូវរបស់ មាស មុត លើឧក្រិដ្ឋកម្មទាំងនោះ ដែលមានលក្ខណៈចាំបាច់ដើម្បីវាយតម្លៃពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត[54]។ ជាការពិតណាស់ ដីកាលើកលែងចោទប្រកាន់ចែងច្បាស់ថា ដីកានេះមិន "បរិយាយពីប្រភេទបទល្មើស ការចាត់ថ្នាក់បទល្មើស ឬទម្រង់នៃការទទួលខុសត្រូវ" ឡើយ[55]។ ក្នុងគោលបំណងផ្តល់យុត្តិកម្មដល់ការខកខានទាំងនេះ មាស មុត លើកឡើងថា "វិធាន ផ្ទៃក្នុងមិនតម្រូវឲ្យមានកម្រិតលម្អិតដូចគ្នាសម្រាប់ដីកាលើកលែងចោទប្រកាន់ឡើយ" ដោយលើកឡើង វិធាន ៦៧(៣) ដែល មាស មុត អះអាងថា មិនត្រូវឲ្យមានការកំណត់ប្រភេទបទល្មើសលើអង្គហេតុសំខាន់ៗ[56]។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលដីកាសម្រេចកលើកលែងចោទប្រកាន់បានទទួលស្គាល់ថា ការវាយតម្លៃលើអ្នកដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងយុត្តាធិការរបស់ អ.វ.ត.ក តម្រូវឲ្យមានការវាយតម្លៃលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានចោទ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ[57]។

---

51 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៤២-១៤៧។

52 ដូចបានពិភាក្សានៅក្នុងឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ២៤ ដែលរកឃើញថា ជនសង្ស័យបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះ គឺសំខាន់បំផុតដល់ការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។

53 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៦០-៦២។

54 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ២០-៣៤។

55 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣។

56 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦១។ អនុលោមតាមវិធាន ៦៧(៣) ស.ច.ស ត្រូវចេញដីកាលើកលែងចោទប្រកាន់ ក្នុងករណី៖ "ក) អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ ខ) ជនប្រព្រឹត្តបទឧក្រិដ្ឋនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ឬ គ) ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ"។

57 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣, ៣៦៥-៣៦៧។ សំណុំរឿង ០០១-សាលក្រមលេខ **E188** ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២២។ *សូមមើល ផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) លើករណីរបស់ អ៊ឹម ចែម កថាខណ្ឌ ៣២១។

ចៅក្រម អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទថា ដើម្បីអនុវត្តសមស្របលើមុខងារត្រួតពិនិត្យឡើងវិញលើបញ្ហាយុត្តាធិការបុគ្គល គឺ "ប្រាកដជាអាចពិនិត្យលើសេចក្តីសន្និដ្ឋាននានាដែលនាំឲ្យមានការសម្រេចបែបនេះ រួមទាំងសេចក្តី សន្និដ្ឋានទាំងឡាយណាដែលពាក់ព័ន្ធនឹងអត្ថិភាពនៃបទល្មើស ឬភវនីយភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ [របស់ ជន ត្រូវចោទ]"[58] ពាក់ព័ន្ធនឹងអង្គហេតុទាំងអស់ដែល ស.ច.ស ទទួលបានពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[59]។

16. ផ្ទុយទៅនឹងការអះអាងដោយគ្មានមូលដ្ឋាននៅក្នុងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ការសម្រេចរបស់ អ.ប.ជ នេះ "មិនមានកំហុស"[60] ឡើយ។ ការខកខានមិនបានផ្តល់សំអាងច្បាប់អំពីទម្រង់នៃការទទួលខុសត្រូវ ធ្វើឲ្យការប៉ុនប៉ងវាយតម្លៃឧក្រិដ្ឋកម្មដែល មាស មុត "ទទួលខុសត្រូវ" ព្រហ្មទណ្ឌ និងកម្រិតនៃការចូលរួមរបស់ មាស មុត មិនអាចធ្វើទៅបាន[61]។ ឆន្ទានុសិទ្ធិរបស់ ស.ច.ស គឺផ្អែកលើការកំណត់ទៅលើថាតើនណាជា "ជនទទួលខុសត្រូវខ្ពស់បំផុត"ចំពោះឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការជាក់ស្តែងរបស់ អ.វ.ត.ក[62]។ ការកំណត់នេះអាចធ្វើទៅបានតែនៅពេលដែលអង្គហេតុត្រូវបានកំណត់ប្រភេទបទល្មើស[63]។ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមានសារៈសំខាន់

---

58 សំណុំរឿង ០០៤/១-**ឯកសារ D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២៦ (មានបញ្ជាក់បន្ថែម)។

59 វិធាន ៦៧(៤)។ សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" កថាខណ្ឌ ៣៣, ៣៧-៣៨។ សាលាវិនិច្ឆ័យ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ សំណុំរឿងលេខ ៧៦-៩១.៩៩២។

60 *ផ្ទុយពី* ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦១។

61 *សូមមើល* សំណុំរឿង ០០១-ឯកសារ **D99/3/42** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ១១៥។

62 *សូមមើល ឧទាហរណ៍* ច្បាប់បង្កើត អ.វ.ត.ក មាត្រា ១៖ ["ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩"]។

63 សំណុំរឿង ០០២-**ឯកសារ D427/3/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ៧៩ [ស.ច.ស ត្រូវតែ "[...] ធ្វើការសម្រេច

សម្រាប់ការវាយតម្លៃលើស្ថានទម្ងន់ ពីព្រោះថា លក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្ម ក៏ដូចជា ឥទ្ធិពលរបស់វាទៅលើជនរងគ្រោះ សុទ្ធតែជាសូចនាករនៃស្ថានទម្ងន់របស់ទង្វើ[64]។ ហេតុដូច្នេះ ការមិនបញ្ចូលការកំណត់ប្រភេទបទល្មើស គឺជាការខកខានមិនបានវាយតម្លៃទៅលើកម្រិតពេញលេញនៃទង្វើឧក្រិដ្ឋរបស់ មាស មុត[65]។

17. លើកំហុសទាំងនេះ ដីកាសម្រេចលើកលែងចោទប្រកាន់បានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុជាច្រើននៅក្នុងការរៀបរាប់អំពី (i) ការបង្ខិតបង្ខំ ការគាបសង្កត់ និងបញ្ជាថ្នាក់លើ[66] និង (ii) ការចូលរួមដោយផ្ទាល់ និងកៀកកិតនឹងឧក្រិដ្ឋកម្ម[67]នៅពេលកំណត់កម្រិតទទួលខុសត្រូវរបស់មាស មុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។ ដីកាសម្រេចលើកលែងចោទប្រកាន់ក៏មានការកំហុសអង្គហេតុបន្ថែមទៀតដែលមានឥទ្ធិពលជាកត្តាកំណត់ជាមូលដ្ឋានលើយុត្តាធិការបុគ្គល[68] និង ការប្រព្រឹត្តិចំពោះជនរងគ្រោះ[69]។ ចំណុចចុងក្រោយ ដីកាសម្រេចលើកលែងចោទប្រកាន់ មានកំហុសអង្គច្បាប់បន្ថែមទៀតដែលសម្រេចថា ឌុច គឺជាជនទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់គត់[70]។

ចុងក្រោយពាក់ព័ន្ធនឹងការកំណត់លក្ខណៈផ្លូវច្បាប់នៃអំពើនានា ដែលបានចោទប្រកាន់ [...] និងសម្រេចលើបញ្ហាថាតើអំពើទាំងនោះចាត់ទុកជាបទឧក្រិដ្ឋនានាដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរទេ"]។

64 ស្ថានភាពស្តីពីនាវាដែលបានចុះបញ្ជីរបស់សហភាព Comoros សាធារណរដ្ឋ Hellenic និងព្រះរាជាណាចក្រកម្ពុជា សំណុំរឿងលេខ ICC-01/13-34 អង្គបុរេជំនុំជម្រះទី I សាលដីកាសម្រេចលើសំណើរបស់សហភាព Comoros ស្នើឱ្យពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចរបស់រដ្ឋអាជ្ញា ផ្តួចផ្តើមបើកការស៊ើបអង្កេត ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ កថាខណ្ឌ ២១។ សំណុំរឿង ០០១-**F28** សាលដីកា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីកាលើករណី *ឌុច*" កថាខណ្ឌ ៣៧៥។ *សូមមើលបន្ថែម* សំណុំរឿង ០០៤/១-**D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៣២៧ (ចៅក្រម Beauvallet និងចៅក្រម Baik)។

65 សំណុំរឿង ០០១-**F28** សាលដីកាលើករណី *ឌុច* កថាខណ្ឌ ២៩៥, ២៩៩។ *សូមមើល ផងដែរ* សាលដីកាលើករណី *Jelisić* ការខ្វែងយោបល់គ្នាដោយផ្នែកខ្លះរបស់ចៅក្រម Shahabuddeen កថាខណ្ឌ ៤២។ *សូមមើលបន្ថែម* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ២៤-២៥។

66 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៨៣-១១១។

67 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១១២-១៣៤។

68 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៣៥-១៥៤។

69 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៥៥-១៧០។ .

70 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៧១-១៩០។

សរុបមក កំហុសទាំងនេះ “ជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តឆន្ទានុសិទ្ធិ[71][របស់ស.ច.ស.ជ] ក្នុងការវាយតម្លៃយុត្តាធិការបុគ្គល។

18. ផ្អែកលើហេតុផលទាំងនេះ ការអះអាងនានារបស់ មាស មុត ដែលថា ដីកាសម្រេចលើកលែងចោទប្រកាន់មោឃភាពដីកាសម្រេចចោទប្រកាន់ មិនត្រឹមត្រូវឡើយ។ ស.ព.អ សូមបញ្ជាក់ពីសេចក្តីសន្និដ្ឋាននៅបណ្តឹងឧទ្ធរណ៍សាជាថ្មីថា សំអាងហេតុនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់លើយុត្តាធិការបុគ្គល គួរតែត្រូវបដិសេធ[72]។

២. ចម្លើយតបទៅនឹងទឡ្ហីករណ៍របស់ មាស មុត លើផលវិបាកនៃដីកាដំណោះស្រាយចំនួនពីរដែលផ្ទុយគ្នា

19. ស.ច.ស.ជ បានចេញដីកាដំណោះស្រាយមួយ ដែល ស.ព.អ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំង ហើយ ស.ព.ជ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចចោទប្រកាន់របស់ ស.ច.ស.អ[73]។ ហេតុដូច្នេះមានលទ្ធភាពផ្សេងៗចំពោះលទ្ធផលនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខ អ.ប.ជ។ មាស មុត យល់ស្របថា ប្រសិនបើ អ.ប.ជ ទទួលបានសំឡេងភាគច្រើនលើសលប់ តាមការតម្រូវ ក្នុងការបដិសេធដីកាសម្រេចលើកលែងចោទប្រកាន់ និងចាត់ទុកដីកាសម្រេចចោទប្រកាន់ជាបានការ សំណុំរឿងនេះគួរតែបញ្ជូនទៅជំនុំជម្រះ។ ប៉ុន្តែ មាស មុត អះអាងដោយមិនត្រឹមត្រូវថា នេះគឺជាស្ថានការណ៍តែមួយគត់ដែលដីកាដំណោះស្រាយផ្ទុយគ្នាពីរនាំដល់ការផ្ទេរសំណុំរឿងទៅ អ.ជ.ស.ដ។

20. ច្បាស់ណាស់ថា ក្រោមបញ្ញត្តិដ៏ច្បាស់លាស់នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ប្រសិនបើ អ.ប.ជ ខកខានមិនបានសំឡេងភាគច្រើនលើសលប់ តាមការតម្រូវ សម្រាប់សេចក្តីសម្រេចលើដីកាសម្រេចចោទប្រកាន់នោះទេ សំណុំរឿងនឹងត្រូវបញ្ជូនទៅ អ.ជ.ស.ដ[74]។ នៅពេល ស.ច.ស មិនយល់ស្របលើសំណុំរឿង

---

[71] *យោង*ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ ទំព័រ ១ កថាខណ្ឌ ៦៦។ *សូមមើល ផងដែរ* ទំព័រ ២ កថាខណ្ឌ ២, ៩, ៤៥, ៤៩, ៦២-៦៦។

[72] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៩១, ២០២-២០៣។

[73] ឯកសារ **D267/3** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ (“បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ”)។

[74] *សូមមើល ខាងក្រោម* កថាខណ្ឌ ២២-៣៨។

ដែលបន្តទៅមុខ និង អ.ប.ជ ខកខានមិនបានសំឡេងភាគច្រើនលើសលប់ ក្នុងការដោះស្រាយការខ្វែងគំនិតគ្នានោះ ការកាត់សេចក្តីលើសំណុំរឿងនេះបន្ត គឺថា សំណុំរឿងនេះត្រូវបញ្ជូនទៅ អ.ជ.ស.ដ។ ការអះអាងរបស់ មាស មុត ដែលថា ដើម្បីឲ្យរឿងក្តីវិវត្តទៅជំហ៊ានបន្ទាប់នៃកិច្ចនីតិវិធី អ.ប.ជ ត្រូវគាំទ្រដីកាសម្រេចចោទប្រកាន់ដោយសំឡេងភាគច្រើនលើសលប់ ដើម្បីឆ្លុះបញ្ចាំងពីនីតិវិធីធ្វើសេចក្តីសម្រេចនៅដំណាក់កាលជំនុំជម្រះ និងដំណាក់កាលប្តឹងឧទ្ធរណ៍[75] មិនសមហេតុផល និងធ្វើឡើង ដោយគ្មានមូលដ្ឋានដែលមានចែងក្នុងច្បាប់ និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក។ វិធានផ្ទៃក្នុង ៧៧(១៣)[76] និង ៧៩(១)[77] សុទ្ធតែបញ្ជាក់ថា ដីកាសម្រេចចោទប្រកាន់ដែលចេញដោយ ក.ស.ច.ស ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ អ.ជ.ស.ដ បើគ្មានការអនុម័តដោយសំឡេងភាគច្រើនលើសលប់ពី អ.ប.ជ។ ជាការពិតណាស់ បណ្តឹងឧទ្ធរណ៍របស់ មាស មុត មិនជំទាស់ជាដុំកំភួនទៅលើដីកាសម្រេចចោទប្រកាន់ឡើយ[78]។

21. ទឡ្ហីករណ៍របស់ មាស មុត ដែលនៅសេសសល់ពាក់ព័ន្ធនឹងផលវិបាក ផ្អែកលើទិដ្ឋភាពនីតិវិធី "ស.ច.ស ចំនួនពីររូបមានឋានៈស្មើគ្នា និងមានឯករាជ្យភាពក្នុងការចេញដីកាដំណោះ ស្រាយដែលមានអានុភាពគតិយុត្តិស្មើគ្នា"[79] ក្រោយពេល អ.ប.ជ សម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងអស់នៅក្នុងរឿងក្តីនេះ។ មានសេណារីយ៉ូប្រាកដនិយមចំនួនពីរ ខណៈដែលដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរនៅមានអានុភាព។ សេណារីយ៉ូទីមួយអាចកើតឡើង ប្រសិនបើ អ.ប.ជ មិនអាចរកសំឡេងភាគច្រើនលើសលប់សម្រាប់សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយ។ សេណារីយ៉ូទីពីរ អាចកើតឡើង ប្រសិនបើ អ.ប.ជ ចេញសេចក្តីសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍ទាំងអស់ដោយយល់ឃើញថា ស.ច.ស.អ នៅក្នុងដីកាសម្រេចចោទប្រកាន់ និង ស.ច.ស.ជ នៅក្នុង

---

75 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ ទំព័រ ១ កថាខណ្ឌ ៤៦, ៦៤, ៧០។

76 វិធាន ៧៧(១៣) ["សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច។ [...]។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវអនុវត្តដូចខាងក្រោម៖ [...] ខ-ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះត្រូវសម្រេចប្តឹង [បញ្ជូនបណ្តឹង] ទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់ ស.ច.ស"]។

77 វិធាន ៧៩(១)៖ ["អង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស ឬ តាមសេចក្តី សម្រេចរបស់ អ.ប.ជ"]។

78 *សូមមើល ខាងលើ* កថាខណ្ឌ ៧-៨។

79 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ ទំព័រ ១។ *សូមមើល ផងដែរ* កថាខណ្ឌ ៣៧, ៤៥, ៦០, ៦៦។

ដីកាសម្រេចលើកលែងចោទប្រកាន់ បានអនុវត្តនៅក្នុងឆន្ទានុសិទ្ធិរបស់ខ្លួន។ នៅក្នុងស្ថានការណ៍ទាំងនេះ មាស មុត តវ៉ាថា សំណុំរឿងប្រឆាំងនឹងខ្លួន គួរតែបដិសេធ[80] ពីព្រោះ (i) ភាគីនៃកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក មិនធ្លាប់មានបំណងចង់ឲ្យសំណុំរឿងឈានដល់ដំណាក់កាលជំនុំជម្រះឡើយ នៅពេលដែលដីកាសម្រេចលើកលែងចោទប្រកាន់ និងដីកាដំណោះស្រាយត្រូវបានចេញដំណាលគ្នា[81]។ (ii) ប្រសិនបើដីកាសម្រេចលើកលែងចោទប្រកាន់ និងដីកាដំណោះស្រាយ ត្រូវបានអនុញ្ញាតឲ្យមានអត្ថិភាព ក្រោមវិធាន៧៧(១៣) លទ្ធផលអាចមិនសមហេតុផល ហើយ សិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ត្រូវបានរំលោភបំពាន[82]។ (iii) ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះដោយផ្អែកលើដីកាសម្រេចចោទប្រកាន់ដែលចេញដោយ ស.ច.ស តែម្នាក់ នឹងរំលោភគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ[83]។

i. កិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងចែងថា ក្នុងករណីដែលដីកាលើកលែងចោទប្រកាន់ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះបានចេញក្នុងពេលដំណាលគ្នា ហើយ អ.ប.ជ ពុំអាចរកបានសំឡេងភាគច្រើនលើសលប់ដើម្បីបដិសេធចោលដីកាណាមួយទេនោះ រឿងក្តីត្រូវបញ្ជូនទៅជំនុំជម្រះ

22. មាស មុត ជំទាស់ថា ភាគីនៃកិច្ចព្រមព្រៀង អ.វ.ត.ក គឺ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ពុំមានចេតនាឲ្យរឿងក្តីបន្តទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ នៅពេលដែលដីកាលើកលែងចោទប្រកាន់ ត្រូវបានចេញក្នុងពេលដំណាលគ្នា ហើយពុំមានដីកាណាមួយក្នុងចំណោមដីកាទាំងពីរត្រូវបានច្រានចោលនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ដោយសំឡេងភាគច្រើនលើសលប់នោះ[84]។ គាត់អះអាងថា ភាគីនៃកិច្ចព្រមព្រៀង អ.វ.ត.ក "មានបំណងទុកស្ថានភាពដីកាដំណោះស្រាយផ្ទុយគ្នានេះចោលដោយគ្មានដំណោះស្រាយនៅណាក់កាល

80 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ ទំព័រ ១, ៤៦ កថាខណ្ឌ ៧២។

81 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៣-៤០។

82 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤១-៤៨, ៦៦។

83 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៥-៤៦, ៤៩-៦៦។

84 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ ទំព័រ ១-២ កថាខណ្ឌ ៣២-៤០។

នៃដីកាដំណោះស្រាយ”[85] ហើយថា “ប្រសិនបើភាគីនៃកិច្ចព្រមព្រៀងចង់ឲ្យរឿងក្តីបន្តទៅមុខ [...] ពួកគាត់ប្រហែលជាបានព្រមព្រៀងគ្នាលើបទប្បញ្ញត្តិច្បាស់លាស់ដែលចែងអំពីលទ្ធផលបែបនេះហើយ”[86]។ ការអះអាងនេះមិនសមហេតុផលឡើយ។ ដោយសារតែគោលបំណងនៃការចចារ និងដំណោះស្រាយដោយសំឡេងភាគច្រើនលើសលប់ គឺដើម្បីដោះស្រាយស្ថានភាពដែល ស.ច.ស ឬសហព្រះរាជអាជ្ញា មានមតិយោបល់ផ្ទុយគ្នា វាប្រាកដជាគ្មានប្រយោជន៍អ្វីឡើយក្នុងការទុកបញ្ហាខ្វែងយោបល់គ្នាដែលអាចកើតមានឡើង ចោលដោយគ្មានដំណោះស្រាយនោះ។

23. ផ្ទុយទៅវិញ ពាក្យពេចន៍ត្រង់ៗនៃកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង និងភ័ស្តុតាងអំពីចេតនាច្បាស់លាស់របស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជានៅពេលដែលភាគីទាំងពីរនេះបានបញ្ចប់កិច្ចព្រមព្រៀង អ.វ.ត.ក បញ្ជាក់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយណាក៏ដោយ ដែលចេញដោយ ស.ច.ស តែម្នាក់[87] ឬ ស.ច.ស ទាំងពីរ ដែល អ.ប.ជ មិនអាចដោះស្រាយបានដោយសំឡេងភាគច្រើនលើសលប់នោះ ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីបន្តរឿងក្តីទៅមុខទៀត។ លទ្ធផលនេះត្រូវយកមកអនុវត្ត បើទោះបីជា ស.ច.ស ដាក់មតិយោបល់របស់ពួកគេដាច់ដោយឡែកពីគ្នានៅចំពោះមុខ អ.ប.ជ តាមរយៈសារណាអំពីករណីខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ឬក៏ ស.ច.ស ចេញដីកាដំណោះស្រាយដោយមានសំអាងហេតុពេញលេញជាងនេះដាក់ជូនទៅ អ.ប.ជ ក៏ដោយ។ ជម្រើសទីពីរនេះគ្រាន់តែជាការផ្តល់ព័ត៌មានបន្ថែមទៀតនៅចំពោះមុខ អ.ប.ជ និងផ្តល់ឲ្យភាគីនូវឱកាសបន្ថែមទៀតក្នុងការផ្តល់ទឡ្ហីករណ៍អំពីការយល់ឃើញរបស់ខ្លួនទៅលើភ័ស្តុតាង រួមទាំងនៅក្នុងករណីនេះផងដែរ ដោយ ស.ច.ស នីមួយៗ ដាក់សេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួនដែលមានកម្រាស់រាប់រយទំព័រ។

---

85 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៩។

86 ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤០។

87 វិធាន ១(២) ចែងបន្ថែមថា៖ [“នៅក្នុងឯកសារនេះ ពាក្យសម្គាល់ឯកវចនៈក៏អាចយល់ជាពហុវចនៈដែរ ហើយក៏អនុវត្តដូចគ្នាផងដែរចំពោះករណីបញ្ច្រាសមកវិញ។ ជាពិសេស លើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ”។ ស.ព.អ កត់សម្គាល់ឃើញថា បទប្បញ្ញត្តិនេះមិនមានការប៉ះពាល់ផ្នែកវេយ្យាករណ៍ណាមួយទៅលើឯកសារនេះជាភាសាខ្មែរនោះទេ ដោយហេតុថា ករណីភាគច្រើននៅក្នុងបទប្បញ្ញត្តិនេះមិនបានញែកចេញពីគ្នារវាងឯកវចនៈ និងពហុវចនៈទេ។ ហេតុដូច្នេះ វិធាន ៧៧(១៣)(ខ) និង៧៩(១) អនុវត្តចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចេញដោយ ស.ច.ស តែម្នាក់បាន ដូចជាករណីនៅចំពោះមុខនេះ។

24. អនុលោមតាមវិធាន ៧៧(១៣)(ខ)នៃវិធានផ្ទៃក្នុង ដែលចែងយ៉ាងច្បាស់នោះ រឿងក្តីត្រូវតែបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង លើកលែងតែដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបាន អ.ប.ជ ច្រានចោលដោយសំឡេងភាគច្រើនលើសលប់។ ប្រសិនបើ អ.ប.ជ មិនអាចរកសំឡេងភាគច្រើនលើសលប់បានទេនោះ វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ចែងអំពីសេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្រគ្រប់គ្រាន់ចំនួនពីរ (i) អនុលោមតាមវិធាន ៧៧(១៣)(ក) "ដីកា ឬកិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ [...] ត្រូវតម្កល់ទុកជាបានការ"[88] និង (ii) អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង។ ទោះបីជាពាក្យ "ដីកា" នៅក្នុងវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង អាចរួមបញ្ចូលដីកាលើកលែងការចោទប្រកាន់ក៏ដោយ[89] ការយកវិធាន ៧៧(១៣)(ក) និង (ខ) ទាំងពីរនេះមកអនុវត្តចំពោះដីកាដំណោះស្រាយដែលផ្ទុយគ្នា នឹងមិននាំឱ្យមាន "លទ្ធផលដែលមិនសមហេតុ

---

[88] វិធាន ៧៧(១៣)(ក)៖ ["សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវអនុវត្តដូចខាងក្រោម៖ ក) ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំមោឃភាពដីកា ឬ កិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬ កិច្ចស៊ើបសួរនោះ ត្រូវតម្កល់ទុកជាបានការ"]។

[89] ស.ព.អ កត់សម្គាល់ឃើញថា អត្ថបទជាភាសាបារាំងនៃវិធានក្នុង មិនរាប់បញ្ចូលដីកាលើកលែងចោទប្រកាន់ទៅក្នុងវិសាលភាពនៃវិធាន ៧៧(១៣)(ក) ទេ។ វិធាន ៧៧(១៣) និងវិធាន ៧៧(១៣)(ក) ចែងថា៖ "Lorsque la majorité requise n'est pas atteinte, la Chambre préliminaire est présumée avoir rendu une décision s'interprétant comme suit: a) Concernant un appel contre une ordonnance ou une requête en annulation d'un acte d'instruction, *autre que l'ordonnance de clôture*, l'ordonnance ou l'acte d'instruction demeure" (មានបញ្ជាក់បន្ថែម)។ ដោយសារពាក្យ "*ordonnance de clôture*" ជាពាក្យទូទៅ ដែលត្រូវបានអនុវត្តចំពោះដីកាដំណោះស្រាយទាំងអស់ (ទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ–"ordonnance de renvoi" និងដីកាលើកលែងចោទប្រកាន់–"ordonnance de non-lieu") នោះពាក្យនេះមិនរាប់បញ្ចូលដីកាលើកលែងចោទប្រកាន់ទៅក្នុងព្រំដែននៃវិធាន ៧៧(១៣)(ក) នោះឡើយ។ អត្ថបទជាភាសាខ្មែរ ក៏ដូចជាភាសាអង់គ្លេស គឺសំដៅទៅ "ដីកា ឬកិច្ចស៊ើបសួរ *ដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ*" (មានបញ្ជាក់បន្ថែម) ដោយអនុញ្ញាតឱ្យដីកាលើកលែងចោទប្រកាន់ស្ថិតនៅក្នុងវិសាលភាពនៃវិធាននោះ។ សំណុំរឿង ០០៤/១ ប្រសិនបើ អ.ប.ជ មិនអាចរកបានសំឡេងភាគច្រើនលើសលប់ចំពោះបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ D261 (ដីកាលើកលែងចោទប្រកាន់) បានទេ នោះ អ.ប.ជ ត្រូវ "ប្រកាសជាឯកច្ឆ័ន្ទថា ដីកាដំណោះស្រាយ (សំអាងហេតុ) លើកលែងការចោទប្រកាន់ប្រឆាំងនឹង អឹម ចែម ត្រូវតម្កល់ទុកជាបានការ" ដោយអនុលោមតាមវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង។ សូមមើលសំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ទំព័រ ២៧ (សេចក្តីសម្រេចជាឯកច្ឆន្ទ)។

ផល” ដែលបន្សល់ទុកដីកាបញ្ជូនរឿងទៅជំនុំជម្រះ “ឲ្យលងបន្លាចលោក មាស មុត គ្មានទីបញ្ចប់”[90] នោះទេ។

25. ផ្ទុយទៅវិញ វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង បញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានច្រានចោលដោយសេចក្ដីសម្រេចតាមសំឡេងភាគច្រើនលើសលប់នៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍ទេនោះ សំណុំរឿងប្រឆាំងនឹង មាស មុត ត្រូវតែបញ្ជូនទៅជំនុំជម្រះ។ វិធាន ៧៧(១៣)(ខ) គឺជា*វិធានពិសេស* ទាក់ទិនទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូច្នេះ វិធាននេះមានអធិកភាពទៅលើពាក្យពេចន៍ទូទៅនៃវិធាន ៧៧(១៣)(ក)។ “ដីកាលើកលែងការចោទប្រកាន់” និង “ដីកាដំណោះស្រាយ” ក៏ដូចជា “ដីកាបញ្ជូនរឿងទៅជំនុំជម្រះ” គឺជាពាក្យពេចន៍ ដែលត្រូវបានកំណត់និយមន័យនៅក្នុងវិធានផ្ទៃក្នុង[91]។ ប្រសិនបើអ្នកធ្វើសេចក្ដីព្រាងវិធានផ្ទៃក្នុងមានបំណងលើកឡើងជាក់លាក់អំពីអានុភាពនៃការខកខានរបស់ អ.ប.ជ ក្នុងការច្រានចោលដីកាលើកលែងការចោទប្រកាន់នោះ ពួកគាត់ប្រាកដជាអាចបញ្ជាក់ឲ្យបានច្បាស់ហើយ។ វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង បង្ហាញអំពីចេតនាក្នុងការអនុវត្តអាណត្តិយ៉ាងច្បាស់លាស់នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក ក្នុងករណីដែលសហព្រះរាជអាជ្ញា ឬ ស.ច.ស ខ្វែងយោបល់គ្នាលើដំណើរការទៅមុខនៃរឿងក្ដី ដោយ អ.ប.ជ មិនអាចរកសំឡេងភាគច្រើនលើសលប់បានទេនោះ រឿងក្ដីត្រូវបន្តទៅដំណាក់កាលបន្ទាប់នៃកិច្ចដំណើរការនីតិវិធី។

26. ផ្ទុយទៅនឹងការអះអាងរបស់ មាស មុត រឿងក្ដីដែលបន្តដំណើរការទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺ*ច្បាស់ណាស់* ជាអ្វីដែលភាគីនៃកិច្ចព្រមព្រៀង អ.វ.ត.ក ចង់បាន ទោះបីជាក្នុងករណីដែលដីកាលើកលែងការចោទប្រកាន់តម្កល់ទុកជាបានការក្នុងពេលជាមួយគ្នាក៏ដោយ។ មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងអំពីគោលការណ៍ណែនាំយ៉ាងច្បាស់ ពាក់ព័ន្ធនឹងបញ្ហាថា តើត្រូវធ្វើយ៉ាងដូចម្ដេច ប្រសិនបើ អ.ប.ជ មិនអាចដោះស្រាយករណីខ្វែងយោបល់គ្នារវាង ស.ច.ស ឬ សហព្រះរាជអាជ្ញាទេនោះ។ មាត្រានេះចែងថា “ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត”[92]។ ស្រដៀងគ្នានេះដែរ នៅទូទាំង

---

90 *ផ្ទុយពី* ឯកសារ **D267/4** បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤២។

91 វិធានផ្ទៃក្នុង ទំព័រ ៨៣-៨៤។

92 កិច្ចព្រមព្រៀងស្ដីពី អ.វ.ត.ក មាត្រា ៧(៤)។ តាមរយៈពាក្យពេចន៍នេះ បទប្បញ្ញត្តិនេះទាក់ទងនឹងយន្តការដោះស្រាយវិវាទផ្លូវការ ដូចមានកំណត់នៅក្នុងមាត្រា ២៣*ថ្មី* នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធាន ៧២ ហើយបទប្បញ្ញត្តិនេះ

កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ក្នុងករណីដែលសហព្រះរាជអាជ្ញា ឬ ស.ច.ស មិនអាចយល់ស្របគ្នាទៅលើបញ្ហាណាមួយ ហើយមិនបានប្ដឹងទៅ អ.ប.ជ អនុលោមតាមមាត្រា ៧ ដែលចែងអំពីយន្តការដោះស្រាយករណីខ្វែងយោបល់គ្នាទេនោះ កិច្ចព្រៀង អ.វ.ត.ក ចែងថា ការចោទប្រកាន់[93] ឬការស៊ើបអង្កេត[94] ត្រូវបន្តដំណើរការទៅមុខទៀត។ មាត្រាទាំងនេះនៃកិច្ចព្រមព្រៀងដែលបានព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិរួចហើយនោះ ផ្ទុះបញ្ចាំងអំពីគោលការណ៍យ៉ាងច្បាស់ក្នុងការធ្វើសេចក្ដីសម្រេចដែលថា ក្នុងករណីដែលមានការខ្វែងយោបល់គ្នា កិច្ចដំណើរការនីតិវិធី គួរតែបញ្ឈប់បានតែតាមរយៈសំឡេងភាគច្រើនលើសលប់របស់ចៅក្រម អ.ប.ជ *ប៉ុណ្ណោះ*។ បើទោះបីជាចៅក្រមម្នាក់យល់ឃើញថាត្រូវបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីជាផ្នែកនៃការស៊ើបអង្កេត ឬជាផ្នែកនៃការចោទប្រកាន់ក៏ដោយ ក្នុងករណីដែល អ.ប.ជ មិនអាចរកសំឡេងភាគច្រើនលើសលប់ក្នុងការច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះទេនោះ ត្រូវប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ហើយរឿងក្ដីត្រូវយកមកជំនុំជម្រះ។

27. នេះក៏ដោយសារតែមាត្រា ៧(៤) ត្រូវតែបកស្រាយដោយពិចារណាទៅដល់ខ្លឹមសារ និង កម្មវត្ថុរបស់វា និងគោលបំណងនៃសន្ធិសញ្ញារវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដោយមិនត្រូវបកស្រាយដាច់ដោយឡែកតែឯកឯងនោះឡើយ[95]។ ដូចមានចែងនៅក្នុងមាត្រា ១ នៃ

មិនបញ្ជាក់ពីស្ថានភាពច្បាស់លាស់នៅក្នុងករណីបច្ចុប្បន្ននេះទេ។ ប៉ុន្តែ វា*ពិតជា*បញ្ជាក់យ៉ាងច្បាស់លាស់ពីស្ថានភាពដែលយើងស្ថិតក្នុងលក្ខណៈចាំបាច់បំផុតៈ ស.ច.ស ទាំងពីរមិនយល់ស្របគ្នា ថាតើដំណើរការនីតិវិធីគួរបន្ត ឬយ៉ាងណានោះ។

93 កិច្ចព្រមព្រៀងស្ដីពី អ.វ.ត.ក មាត្រា ៦(៤)។ *សូមមើលផងដែរ* ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ២០ថ្មី។ វិធាន ៧១។

94 កិច្ចព្រមព្រៀងស្ដីពី អ.វ.ត.ក មាត្រា ៥(៤)។ *សូមមើលផងដែរ* ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ថ្មី។ វិធាន ៧២។

95 អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ លេខ 1155 UNTS 331 មាត្រា ៣១(១)៖ ["សន្ធិសញ្ញាត្រូវតែបកស្រាយប្រកបដោយសុចរិត ស្របតាមន័យអត្ថន័យធម្មតាដែលត្រូវបានផ្ដល់ចំពោះពាក្យពេចន៍នៃសន្ធិសញ្ញានេះ នៅក្នុងបរិបទនៃពាក្យពេចន៍ទាំងនេះ និងយោងតាមកម្មវត្ថុ និងគោលបំណងរបស់វា"]។ *សូមមើលផងដែរ ឧ. ធម្មនុញ្ញនៃគណៈកម្មាធិការសុវត្ថិភាពដែនទឹករបស់អង្គការពិគ្រោះយោបល់ផ្នែកដែនទឹកអន្តររដ្ឋាភិបាល* យោបល់ប្រឹក្សា ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៦០ របាយការណ៍របស់ ICJ ឆ្នាំ១៩៦០ ទំព័រ ១៥០ កថាខណ្ឌ ១៥៨ ["ពាក្យនេះមានពីអត្ថន័យរបស់វាចេញមកពីបរិបទដែលត្រូវបានប្រើពាក្យនេះ"]។ *លក្ខខណ្ឌបម្រុងចំពោះអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍* យោបល់ប្រឹក្សា ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៥១ របាយការណ៍របស់ ICJ ឆ្នាំ១៩៥១ ទំព័រ ១៥ កថាខណ្ឌ ២៤។ សិទ្ធិរបស់ជនជាតិនៃសហរដ្ឋអាមេរិកនៅក្នុងប្រទេសម៉ារ៉ុក (ប្រទេសបារាំង ទល់នឹង សហរដ្ឋអាមេរិក) សាលក្រម

កិច្ចព្រមព្រៀង អ.វ.ត.ក គោលបំណងនោះគឺដើម្បី "កំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា *ដើម្បីកាត់សេចក្តី* មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានាក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ[96]។ បន្ទាប់មក គោលបំណងនោះក៏បានឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងមាត្រា ១ នៃច្បាប់ អ.វ.ត.ក[97]។ ស្រដៀងគ្នានេះដែរ ចំណងជើងពេញលេញ[98] នៃកិច្ចព្រមព្រៀង អ.វ.ត.ក[99] និងច្បាប់ អ.វ.ត.ក[100] ក៏បង្ហាញផងដែរថា ភាគីនៃកិច្ចព្រមព្រៀងយល់ថា ខ្លួនកំពុងកំណត់ "ការចោទប្រកាន់" ទាំងមូលទៅលើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះ

ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៥២ របាយការណ៍របស់ ICJ ឆ្នាំ១៩៥២ ទំព័រ ១៧៦ កថាខណ្ឌ ១៩៦។ *សូមមើល បន្ថែម ឧ. ករណី Corfu Channel (ចក្រភពអង់គ្លេស ទល់នឹង ប្រទេសអាល់បានី) សាលក្រម* ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៤៩ របាយការណ៍របស់ ICJ ឆ្នាំ១៩៤៩ ទំព័រ ៤ កថាខណ្ឌ ២៤ ["ពិតហើយ វាអាចមានវិសមិតភាពជាមួយនឹងវិធាននៃការបកស្រាយដែលគេទទួលយកជាទូទៅ ដើម្បីទទួលស្គាល់ថា បទប្បញ្ញត្តិប្រភេទនេះ ដែលកើតមាននៅក្នុងកិច្ចព្រមព្រៀងពិសេសមួយ មិនគួរមានការបញ្ជាក់អះអាង ឬប្រសិទ្ធភាពអ្វីឡើយ"] ការជួសជុលសំណងសម្រាប់ព្យសនកម្មដែលបានទទួលនៅក្នុងការផ្តល់សេវារបស់អង្គការសហប្រជាជាតិ (យោបល់ប្រឹក្សា) ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៤៩ របាយការណ៍របស់ ICJ ឆ្នាំ១៩៤៩ ទំព័រ ១៧៤ កថាខណ្ឌ ១៧៩ និងកថាខណ្ឌបន្តបន្ទាប់ [ដែលសន្និដ្ឋានទៅលើឋានៈ និងសមត្ថភាពជាក់លាក់របស់ អ.ស.ប ពីការដែលថា បើមិនមាន អ.ស.ប ទេ គេមិនអាចទទួលខុសត្រូវលើដំណើរការនានាដែលមានបំណងចង់បាននោះទេ]។ *ការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ (ប្រទេសហ្ស៊កហ្ស៊ី ទល់នឹង សហព័ន្ធរុស្ស៊ី)* អញ្ញត្រកម្ម សាលក្រម ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ របាយការណ៍របស់ ICJ ឆ្នាំ២០១១ ទំព័រ ៧០ កថាខណ្ឌ ១៣៣-១៣៤។

96 សូមមើល ផងដែរ កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក ["ដោយហេតុថា នៅមុនពេលចរចាលើកិច្ចព្រមព្រៀងនេះ មានការរីកចម្រើនជាច្រើនធ្វើឡើង [...] ឈានទៅរកការបង្កើតនូវអង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ ដោយមានជំនួយពីអន្តរជាតិ" (មានសេចក្តីបញ្ជាក់បន្ថែម)]។

97 ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១ ចែងថា "ច្បាប់នេះរៀបចំឡើងដើម្បីវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យ។

98 អត្ថបទទាំងមូលនៃសន្ធិសញ្ញាត្រូវបានយកមកពិចារណាជា "បរិបទ" រួមទាំងចំណងជើងរបស់វាផងដែរ។ *សូមមើល ឧទាហរណ៍* វេទិកាប្រេង (សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ទល់នឹង សហរដ្ឋអាមេរិក) អញ្ញត្រកម្ម សាលក្រម ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៦ របាយការណ៍របស់ ICJ ឆ្នាំ១៩៩៦ ទំព័រ ៨០៣ កថាខណ្ឌ ៤៧។

99 "កិច្ចព្រមរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តី [...] នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ"។

100 "ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ"។

អំពើឃោរឃៅក្នុងរបបខ្មែរក្រហម។ នៅក្នុងបរិបទនេះ វាបង្ហាញយ៉ាងច្បាស់ថា "ការស៊ើបអង្កេត ឬការចោទប្រកាន់ត្រូវដំណើរការទៅមុខ" ពោលគឺមានន័យយ៉ាងសាមញ្ញថា "រឿងក្តីត្រូវបន្ត ដំណើរការទៅមុខ" និងរួមបញ្ចូលទាំងដំណាក់កាលនៃការប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

28. លទ្ធផលនេះស៊ីសង្វាក់គ្នាជាមួយនឹងអត្ថន័យ និងទម្រង់នៃកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ដែលក្តោបបញ្ចូលគោលការណ៍ដែលថា ស.ច.ស និងសហព្រះរាជអាជ្ញា អាចបំពេញកិច្ចដោយឯករាជ្យដើម្បីជំរុញកិច្ចដំណើរការនីតិវិធីទៅមុខ និងគោលការណ៍មួយដែលចង់ឲ្យកិច្ចដំណើរការនីតិវិធីបន្តទៅមុខ ក្នុងករណីដែលការខ្វែងយោបល់គ្នាមិនអាចដោះស្រាយបាន[101]។ អ.ប.ជ ជានិច្ចកាល បានគាំទ្រគោលការណ៍នេះ[102]។

29. ចំណុចនេះក៏ស៊ីសង្វាក់គ្នាទាំងស្រុងផងដែរជាមួយនឹងជំហររបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិនៅក្នុងអំឡុងពេលនៃការចចារបង្កើតកិច្ចព្រមព្រៀង អ.វ.ត.ក។ ពុំមានចំណុចណាមួយនៅក្នុងកំណត់ហេតុនៃកិច្ចចចារនោះ គាំទ្រដល់ការអះអាងដែលគ្មានមូលដ្ឋានរបស់ មាស មុត ដែលថា រាជរដ្ឋាភិបាលកម្ពុជា ឬអង្គការសហប្រជាជាតិ "មានបំណងទុកស្ថានភាពដីកាដំណោះស្រាយផ្ទុយគ្នានេះចោល ដោយគ្មានដំណោះស្រាយនៅដំណាក់កាលនៃដីកាដំណោះស្រាយ"[103]

---

[101] *សូមមើល* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤), ៦(៤), ៧(៤)។ ច្បាប់ អ.វ.ត.ក មាត្រា ២០*ថ្មី*, ២៣*ថ្មី*។ វិធាន ៧១, ៧២, ៧៧(១៣) នៃវិធានផ្ទៃក្នុង។

[102] *សូមមើលឧទាហរណ៍* **ឯកសារ** D1/1.3 សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១៦, ២៦, ៤៥។ **ឯកសារ** D120/3/1/4.1.12 សេចក្តីសម្រេចទៅលើសំណើជាបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំឲ្យការអនុវត្តដីកាកោះហៅអ្នកស្រីឲ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៤។ **ឯកសារ** D117/1/1/2 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៦។ **ឯកសារ** D128/1/7.1.4 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [កោសលុប] ជំទាស់ទៅនឹងការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ៧។ **ឯកសារ** D128/1/7.1.5 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [កោសលុប] ប្រឆាំងដីកាសម្រេចលើញត្តិរបស់ជនសង្ស័យ ស្នើសុំព័ត៌មានអំពីកំណត់ហេតុនៃការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ១១។

[103] **ឯកសារ** D267/4 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤។

នោះឡើយ។ ស.ព.អ អះអាងថា ប្រសិនបើវាជាចេតនារបស់អ្នកធ្វើសេចក្តីព្រាងក្នុងការដក ដំណាក់កាលនៃដីកាដំណោះស្រាយចេញពីយន្តការដែលពួកគាត់កំពុងបង្កើតឡើងដើម្បីដោះស្រាយ ចំពោះការរំពឹងទុកជាមុនដ៏សមហេតុផលដែលថា ស.ច.ស និងសហព្រះរាជអាជ្ញា អាចខ្វែង យោបល់គ្នានោះ ពួកគាត់ប្រាកដជាបញ្ជាក់ច្បាស់អំពីចំណុចនេះនៅក្នុងអំឡុងការចចារ និង ប្រហែលជាមានចែងអំពីចំណុចនេះនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ជាក់ជាមិនខាន។

30. ប៉ុន្តែ ពួកគាត់មិនបានធ្វើការបញ្ជាក់ដូច្នោះឡើយ។ លទ្ធភាពនៃការស៊ើបអង្កេត ហើយក្រោយមក ទៀតមិនមានការជំនុំជម្រះ ជាដំណោះស្រាយចំពោះការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ឬ ស.ច.ស អំពីថាតើត្រូវបន្តកិច្ចដំណើរការនីតិវិធីទៅមុខ ឬយ៉ាងណានោះ មិនត្រូវបានភាគីនៃកិច្ច ព្រមព្រៀងប្រមើលទុកជាមុនឡើយ ហើយពិតណាស់វាប្រាកដជាវិធានការវិសាមញ្ញមួយ។ ការ បង្កើតប្រព័ន្ធមួយដែលករណីខ្វែងយោបល់គ្នាពីដំបូង ត្រូវដោះស្រាយជាប្រយោជន៍ដល់កិច្ច ដំណើរការនីតិវិធី ប៉ុន្តែក្រោយមកទៀត ករណីខ្វែងយោបល់គ្នារវាងមន្ត្រីដដែលទៅលើបញ្ហាដដែល ត្រូវដោះស្រាយជាប្រយោជន៍ដល់ការបញ្ចប់កិច្ចដំណើរការនីតិវិធីនោះ គឺជាការបង្កើតប្រព័ន្ធមួយ ដែលបានចំណាយធនធានពេលវេលា និងកិច្ចខិតខំប្រឹងប្រែងយ៉ាងសម្បើមក្នុងការស៊ើបអង្កេត ដោយមានក្តីសង្ឃឹមតិចតួចក្នុងការបន្តបញ្ជូនទៅជំនុំជម្រះ។ ស.ព.អ អះអាងថា វាប្រាកដជាមិន ទំនងទាល់តែសោះដែលគេចង់បានប្រព័ន្ធនេះ។ ដោយពិចារណាទៅលើពាក្យពេចន៍នៃកិច្ចព្រម ព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ច្បាស់ណាស់ថា នៅក្នុងករណីរបស់ អ.វ.ត.ក នេះ វាមិនមែនជាប្រព័ន្ធបែបនេះឡើយ។

31. នៅក្នុងថ្ងៃដែលអង្គការសហប្រជាជាតិបានផ្តល់ពាក្យពេចន៍នៃមាត្រា ៧(៤) ជាលើកដំបូងឱ្យទៅ រាជរដ្ឋាភិបាលកម្ពុជា លោក Hans Corell អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ និងជា ទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិ បានកត់ត្រាកិច្ចសន្ទនាមួយជាមួយឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលជាប្រធានអ្នកចចាររបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបដិសេធសំណើរបស់គាត់ ស្នើសុំឱ្យមានលក្ខខណ្ឌតម្រូវសំឡេងភាគច្រើនលើសលប់ ដើម្បី*សម្រេច* ទៅលើការបន្តការស៊ើប អង្កេត ឬការចោទប្រកាន់។ លោក Hans Corell បានពន្យល់ថា យន្តការដោះស្រាយការខ្វែង យោបល់គ្នាដូចដែលបានពង្រាងនោះមានន័យថា “លោក/លោកស្រី ចាំបាច់ត្រូវរកឱ្យបានសំឡេង ភាគច្រើនលើសលប់ ដើម្បីបញ្ឈប់ការស៊ើបអង្កេត ឬការចោទប្រកាន់”[104]។ លោក Hans Corell

[104] **ឯកសារ D267/4.1.5** លិខិតរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ផ្ញើជូននាយករដ្ឋមន្ត្រី ឯកឧត្តម ហ៊ុន សែន ចុះ

បានបញ្ជាក់ជំហរនេះកាលពីខែមីនា ឆ្នាំ២០០៣ បន្ទាប់ពីមានការព្រមព្រៀងគ្នាទៅលើកិច្ចព្រមព្រៀង អ.វ.ត.ក ដែលមានបញ្ចូលពាក្យពេចន៍ដូចគ្នានេះ[105]។

32. លោក David Scheffer ដែលជាឯកអគ្គរដ្ឋទូតគោចររបស់អង្គការសហប្រជាជាតិទទួលបន្ទុកបញ្ហាឧក្រិដ្ឋកម្មសង្គ្រាម និងបានចូលរួមយ៉ាងច្រើននៅក្នុងកិច្ចចចារ[106] មានទស្សនៈដូចគ្នានេះដែរ។ គាត់បានបញ្ជាក់ថា អនុលោមតាមវិធានមតិភាគច្រើនលើសលប់ "វិធីតែមួយគត់ដែលការចោទប្រកាន់ ឬការស៊ើបអង្កេតត្រូវបានបញ្ឈប់ គឺនៅក្នុងករណីដែល [អ.ប.ជ] សម្រេចតាមមតិភាគច្រើនលើសលប់ថា កិច្ចនោះគួរតែបញ្ចប់"[107]។ កាលពីដំណើរការដំបូង នៅពេលដែលក្របខណ្ឌនីតិវិធីប្រមើលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវចេញដោយសហព្រះរាជអាជ្ញា នៅពេលមានការផ្តល់អនុសាសន៍ពី ស.ច.ស លោក David Scheffer បានស្នើឡើងនូវវិធានមតិភាគច្រើនលើសលប់នៅចំពោះមុខ "កិច្ចប្រជុំវិសាមញ្ញ" (ដែលជាអង្គភាព អ.ប.ជ ពីមុន) ជាដំណោះស្រាយមួយចំពោះការខ្វែងយោបល់គ្នា ដែលរារាំងមិនឲ្យរឿងក្តីបន្តដំណើរការទៅជំនុំជម្រះ៖

ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ ភ្ជាប់ជាមួយកំណត់ហេតុរបស់ Hans Corell ផ្ញើជូនអគ្គលេខាធិការ កម្មវត្ថុ៖ ការអំពាវនាវជាបន្ទាន់ពីកម្ពុជា - ជម្រើសនានាក្នុងការដោះស្រាយភាពខុសគ្នារវាងសហចៅក្រមស៊ើបអង្កេត/សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ EN 01614369 (ភាសាអង់គ្លេស)។

105 **ឯកសារ D181/2.36** សេចក្តីថ្លែងការណ៍របស់អគ្គលេខាធិការរង Hans Corell បន្ទាប់ពីចាកចេញពីរាជធានីភ្នំពេញនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ EN 01326112 (ភាសាអង់គ្លេស) ["នឹងមានសហចៅក្រមស៊ើបអង្កេតពីររូប និងសហព្រះរាជអាជ្ញាពីររូប។ នៅក្នុងករណីទាំងពីរ មានមន្ត្រីជាតិមួយរូប និងមន្ត្រីអន្តរជាតិមួយរូប។ ក្នុងករណីដែលមន្ត្រីទាំងពីររូបមានយោបល់ផ្ទុយគ្នាទៅលើបញ្ហាថា តើគួរ ឬមិនគួរបន្តដំណើរការស៊ើបអង្កេត ឬចោទប្រកាន់នោះ ភាពខុសគ្នានោះគួរត្រូវបានដោះស្រាយដោយអង្គបុរេជំនុំជម្រះ ដែលរួមមាន ចៅក្រមជាតិ ៣ (បី) រូប និងចៅក្រមអន្តរជាតិ ២ (ពីរ) រូប។ នៅក្នុងអង្គជំនុំជម្រះនេះ យ៉ាងហោចណាស់ត្រូវបានចៅក្រម ៤ (រូប) ឯកភាពគ្នាដើម្បីបញ្ឈប់ការស៊ើបអង្កេត ឬការចោទប្រកាន់។ ប្រសិនបើមិនសម្រេចបានសម្លេងភាគច្រើននេះទេ ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងបន្តដំណើរការទៅមុខ"]។

106 **ឯកសារ D170.1.7** Scheffer D.J. *ប្រវត្តិនៃការចរចានៃការបង្កើតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក* Cambodia Tribunal Monitor ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១ EN 01168931 (ភាសាអង់គ្លេស) ["ការចូលរួមរបស់ខ្ញុំផ្ទាល់នៅក្នុងដំណើរការចរចា [គឺ] តំណាងឲ្យផលប្រយោជន៍សហរដ្ឋអាមេរិកផង និងដើរតួនាទីជាអ្នកសម្របសម្រួលជាក់ស្តែងរវាងអ្នកចរចាកម្ពុជា និង អ.ស.ប"], EN 01168939 (ភាសាអង់គ្លេស)។

107 David Scheffer នៅក្នុង M. Cherif Bassiouni (កែសម្រួល) "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" *International Criminal Law* ការកែសម្រួលលើកទី៣ វ៉ុល III ឆ្នាំ២០០៨ ("Scheffer នៅក្នុង Bassiouni") ទំព័រ ២៤៦ (ភាសាអង់គ្លេស)។

នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០០ ខ្ញុំបានដាក់លិខិតមួយជូនទៅមេធាវីអង្គការសហប្រជាជាតិ ដែលរួមមានសំណើអំពីរបៀបដោះស្រាយការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីរទៅលើបញ្ហាថាតើ ត្រូវចោទប្រកាន់ ឬមិនត្រូវចោទប្រកាន់ជនសង្ស័យ ដែលចំណុចនេះជាក្តីកង្វល់ដ៏ធំមួយរបស់លោក Corell។ ចម្លើយដែលខ្ញុំបានស្នើឡើងចំពោះបញ្ហានេះ គឺតម្រូវឱ្យមានការពិនិត្យឡើងវិញទៅលើករណីខ្វែងយោបល់គ្នា ដោយ "កិច្ចប្រជុំវិសាមញ្ញ" នៃអង្គជំនុំជម្រះសាលាដំបូង។ សំឡេងមតិភាគច្រើនលើសលប់របស់ចៅក្រមនៅក្នុងកិច្ចប្រជុំវិសាមញ្ញនោះ តម្រូវឱ្យមានជាចាំបាច់ដើម្បីតម្កល់សេចក្តីសម្រេចពិសេសរបស់សហព្រះរាជអាជ្ញាម្នាក់ *មិន*ធ្វើការចោទប្រកាន់។ ប្រសិនបើមិនមានសំឡេងភាគច្រើនលើសលប់ដែលតម្រូវទេនោះ សេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញាម្នាក់ទៀតដែលធ្វើការចោទប្រកាន់ នឹងត្រូវតម្កល់ជាបានការ ហើយរឿងក្តីត្រូវបន្តដំណើរការទៅជំនុំជម្រះ។ នៅក្នុងលិខិតមួយបន្ថែមទៀត ដែលខ្ញុំបានពង្រាងក្រោយមកទៀតនៅក្នុងខែមករា ខ្ញុំបានស្នើឡើងថា ករណីខ្វែងយោបល់គ្នារវាង [ស.ច.ស] ទាំងពីរ ក៏ត្រូវដោះស្រាយស្រដៀងគ្នានេះដែរ ដោយ "អង្គជំនុំជម្រះវិសាមញ្ញ [ដែលដាក់ជំនួស "កិច្ចប្រជុំ"] នៃអង្គជំនុំជម្រះសាលាដំបូង"។ ដំណោះស្រាយនេះមានន័យថា សំឡេងភាគច្រើនលើសលប់របស់អង្គជំនុំជម្រះវិសាមញ្ញនេះ តម្រូវឱ្យមានជាចាំបាច់ដើម្បីតម្កល់សេចក្តីសម្រេចរបស់ [ស.ច.ស] ម្នាក់ដែលមិនបន្តធ្វើការស៊ើបអង្កេត ឬផ្តល់អនុសាសន៍ដល់សហព្រះរាជអាជ្ញាថាមានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ជនសង្ស័យ។ ប្រសិនបើគ្មានសំឡេងភាគច្រើនលើសលប់ដែលតម្រូវទេនោះ ការស៊ើបអង្កេត ឬអនុសាសន៍ឱ្យធ្វើការចោទប្រកាន់ នឹងបន្តដំណើរការទៅមុខ"[108]។

33. ការសម្រេចជាឯកច្ឆ័ន្ទរបស់ចៅក្រមអង្គជំនុំជម្រះតុលាការកំពូលទាំងប្រាំពីររូប (អ.ជ.ក.ត) នៅក្នុងសំណុំរឿង ០០១ និងចៅក្រម អ.ប.ជ ទាំងប្រាំរូប នៅក្នុងសំណុំរឿង ០០២ នៃ អ.វ.ត.ក ក៏អះអាងផងដែរថា ការបកស្រាយវិធាន ៧៧(១៣) និងវិធាន ៧៩(១) នៃវិធានផ្ទៃក្នុងដែលយកមកអនុវត្តយ៉ាងត្រឹមត្រូវតែមួយគត់ចំពោះច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង អ.វ.ត.ក គឺការបកស្រាយដែលបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

---

108 Scheffer នៅក្នុង Bassiouni ទំព័រ ២៣១ (ភាសាអង់គ្លេស) (គូសបញ្ជាក់បន្ថែម)។

34. នៅក្នុងសាលដីកាសំណុំរឿង ០០១ អ.ជ.ត.ក សម្រេចថា៖

> ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា [គ្មាន]សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទគឺជា ឬមិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[109]។

ទោះបីជា អ.ជ.ត.ក ប្រើប្រាស់ឃ្លា "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ" ដោយសារតែអង្គជំនុំជម្រះដកស្រង់ផ្ទាល់ចេញពីច្បាប់ អ.វ.ត.ក ក៏ដោយ ក៏ការបកស្រាយសមហេតុផលតែមួយគត់នៅលើប្រយោគនេះ គឺជាថ្មីម្តងទៀតបង្ហាញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងបន្តដំណើរការទៅជំនុំជម្រះ—ពុំមានន័យផ្សេងទៀតឡើយដែលអ្វីមួយអាច "ដំណើរការទៅមុខ" នៅដំណាក់កាលដែល អ.ជ.ត.ក កំពុងតែពិភាក្សា (ឧទា. នៅពេលដែលមានការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាលើកលែងការចោទប្រកាន់ផ្ទុយគ្នានេះ)។ ដោយហេតុថា វិធានផ្ទៃក្នុងកំណត់ "ដំណាក់កាលជំនុំជម្រះ" ថា "សំដៅទៅដល់កាលបរិច្ឆេទដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានរឿងក្តីយកមកពិនិត្យ"[110] អ.ជ.ត.ក ចាត់ទុក "ការស៊ើបអង្កេត" ថា កំពុងបន្តដំណើរការរហូតដល់ពេលដែល អ.ប.ជ អនុវត្តភារកិច្ចរបស់ខ្លួនក្នុងការប្តឹងទៅអង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចមានចែងនៅក្នុងវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ដែលនៅពេលនោះហើយ "ដំណាក់កាលជំនុំជម្រះ" ចាប់ផ្តើម។

35. ផ្ទុយពីការអះអាងរបស់ មាស មុត[111] ទោះបីជា អ.ជ.ត.ក បានលើកឡើងនីតិវិធីផ្លូវការសម្រាប់ដំណោះស្រាយវិវាទអនុលោមតាមមាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក និងវិធាន ៧២ ដែល ស.ច.ស ណាម្នាក់ ឬ ស.ច.ស ទាំងពីរ បានបញ្ជូនបញ្ហាដីកាសម្រេចលើកលែងការចោទប្រកាន់ និងដីកា

---

[109] សំណុំរឿង ០០១-ឯកសារ **F28** *សាលដីកាសំណុំរឿង ឌុច* កថាខណ្ឌ ៦៤ *ដកស្រង់* ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៧(៤) វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។

[110] វិធានផ្ទៃក្នុង សន្ទានុក្រម ទំព័រ ១៣៧។

[111] **ឯកសារ D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៥-៣៧។

បញ្ជូនរឿងទៅជំនុំជម្រះ ពីរខ្វែងគ្នា ជូន អ.ប.ជ សម្រេចក៏ដោយ លទ្ធផលចម្បងលើបញ្ហានេះគឺអាចអនុវត្តបានដូចគ្នាចំពោះស្ថានភាពបច្ចុប្បន្នក្នុងករណី អ.ប.ជ បានទទួលបណ្តឹងឧទ្ធរណ៍ពីភាគី។ វិធីដែល អ.ប.ជ បានទទួលបញ្ហាចោទមួយនេះ គឺថាតើ ស.ច.ស ណាម្នាក់មានកំហុសនៅក្នុងការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺពុំពាក់ព័ន្ធនោះឡើយ។ មាស មុត ពុំបានបង្ហាញហេតុផល ហើយជាក់ស្តែងគ្មានហេតុផលណាមួយទាល់តែសោះបង្ហាញថា ហេតុអ្វីវិធីដែលបញ្ហាចោទដូចគ្នានេះបានដាក់ជូន អ.ប.ជ គួរមានផលប៉ះពាល់លើលទ្ធផលនៃបញ្ហាចោទនេះ។

36. នៅក្នុងសំណុំរឿង ០០២ អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទ (នៅក្នុងសាលដីកាដែលបានចេញមុនសេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០១) ថា ឃ្លា "ការស៊ើបអង្កេតត្រូវបន្ត" រួមបញ្ចូលឃ្លាដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវដាក់ជូនអង្គជំនុំជម្រះសាលាដំបូង។ ម្យ៉ាងវិញទៀត វាអនុវត្តដូច្នេះនៅក្នុងបរិបទនៃការខ្វែងយោបល់គ្នារវាង ស.ច.ស ពាក់ព័ន្ធនឹងខ្លឹមសារនៃដីកាដំណោះស្រាយ ដែល ស.ច.ស បានជ្រើសរើសមិនបញ្ជូនទៅ អ.ប.ជ ដូចនៅក្នុងសំណុំរឿង ០០៣។ ក្រោយពេលមានការយល់ឃើញខុសគ្នានៅអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០១ លើករណីថាតើបទចោទចំពោះឧក្រិដ្ឋកម្មអនុលោមតាមមាត្រា ៣ថ្មី នៃច្បាប់ អ.វ.ត.ក (បទល្មើសក្រោមច្បាប់ជាតិអនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦) ស្របគ្នាជាមួយនឹងគោលការណ៍នីត្យានុកូលភាពដែរឬទេ ស.ច.ស ពុំយល់ស្របថាតើគួរបញ្ជូនជនត្រូវចោទទាំងបួននៅក្នុងសំណុំរឿង ០០២ ទៅជំនុំជម្រះចំពោះបទល្មើសក្រោមច្បាប់ជាតិនេះឡើយ។ ដោយមើលឃើញថាខ្លួនស្ថិតនៅក្នុង "នីតិវិធីមួយដែលពុំអាចដោះស្រាយបាន" ប៉ុន្តែ ដោយព្រួយបារម្ភថា ការបញ្ជូនការខ្វែងយោបល់គ្នាទៅ អ.ប.ជ អនុលោមតាមវិធាន ៧២ នឹងបណ្តាលឲ្យមានការពន្យារពេល[112]

---

[112] សំណុំរឿង ០០២-**ឯកសារ D427** ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ("ដីកាដំណោះស្រាយ") កថាខណ្ឌ ១៥៧៤ ["ឆ្លងតាមការបកស្រាយមកខាងលើ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតកំពុងប្រឈមនឹងបញ្ហានីតិវិធីមួយដែលមិនអាចដោះស្រាយបាន ដែលបញ្ហានេះមានជាប់ពាក់ព័ន្ធមួយផ្នែកទៅនឹងរចនាសម្ព័ន្ធចម្រុះរបស់ អ.វ.ត.ក. ។ សហចៅក្រមស៊ើបអង្កេតបានព្យាយាមតាក់តែងនូវគោលជំហររួមមួយស្តីអំពីបញ្ហានៃការកំណត់បទល្មើសត្រួតគ្នាចំពោះអង្គហេតុតែមួយ និងបញ្ហាអាជ្ញាយុកាលចំពោះបទល្មើសជាតិ ក៏ដូចជាអំពីវិសាលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ប៉ុន្តែការងារនេះមិនទទួលបានលទ្ធផលនោះឡើយ។ ដោយឋិតក្នុងស្ថានភាពលំបាកបែបនេះ និងដើម្បីជៀសវាងភាពទ័លច្រកនានា ដោយមិនចាំបាច់ឲ្យមានការប្រើប្រាស់នីតិវិធីនៃការដោះស្រាយការខ្វែងយោបល់ដែលអាចនឹងប៉ះពាល់ដល់ដំណើរការតុលាការទាំងមូល និងដោយពិចារណាទៅលើកាតព្វកិច្ចរបស់ខ្លួនក្នុងការចេញសេចក្តីសម្រេចមួយក្នុងថិរៈវេលាសមស្រប ដូចមានចែងក្នុងវិធាន

ស.ច.ស បានបង្គាប់ឲ្យបញ្ជូនជនត្រូវចោទទៅជំនុំជម្រះលើបទចោទទាំងនោះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[113]។

37. នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អៀង សារី បានតវ៉ាមិនខុសពី មាស មុត ថា ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះលើបទចោទទាំងនេះ បានរំលោភលើសច្ចធារណ៍និរទោស ហើយ វិមតិសង្ស័យទាំងអស់ត្រូវបានជាប្រយោជន៍ដល់គាត់។ គាត់ក៏បានតវ៉ាទៀតថា នីតិវិធីស្តីពីការខ្វែងយោបល់គ្នានៅក្នុងវិធាន ៧២ មានភាពចាំបាច់ត្រូវអនុវត្តតាម ហើយ ស.ច.ស បានបំពេញកិច្ច*ហួសដែនសិទ្ធិអំណាច*របស់ខ្លួន ដោយបានជ្រើសរើសដំណើរការនីតិវិធីដោយពុំបានបញ្ជូនបញ្ហានេះទៅ អ.ប.ជ អនុលោមតាមយន្តការនៃការខ្វែងយោបល់គ្នា[114]។ ក្រោយពីបានពិនិត្យឡើងវិញ អ.ប.ជ បានសម្រេចថា៖

> អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតមិនយល់ស្របទៅតាមសំអាងហេតុផ្លូវច្បាប់លើបញ្ហាថាតើ ជនជាប់ចោទគួរ ឬមិនគួរយកទៅជំនុំជម្រះចំពោះបទឧក្រិដ្ឋថ្នាក់ជាតិទេ។ ទោះជាយ៉ាងណាក្តី សហចៅក្រមស៊ើបអង្កេត "បានសម្រេចឯកភាពទទួលយកសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា" និងបានយល់ស្របទៅនឹងសេចក្តីសន្និដ្ឋានបញ្ជូនជនជាប់ចោទទៅជំនុំជម្រះពីបទឧក្រិដ្ឋថ្នាក់ជាតិ។ <u>ការធ្វើបែបនេះដែលផ្ទុយពីការអះអាងរបស់សហមេធាវីការពារក្តីមិនបានបង្កើតជាការរំលោភដល់សិទ្ធិរបស់ជនជាប់ចោទដោយត្រូវសន្មតថាគ្មានទោស ឬ ការចេញសេចក្តីសម្រេចដែលហួសពីសិទ្ធិអំណាចរបស់ខ្លួន ដោយខកខានមិនបានអនុវត្តតាមនីតិវិធីនៃការខ្វែងយោបល់គ្នាដែលមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុងនោះឡើយ</u>។ សហចៅក្រមស៊ើបអង្កេតមិនមានកាតព្វកិច្ចក្នុងការជូនដំណឹងដល់អង្គបុរេជំនុំជម្រះទេ នៅពេលខ្លួនមិនព្រមព្រៀងគ្នាលើបញ្ហាណាមួយដែលនៅចំពោះមុខ ហើយក្នុងករណីនេះ <u>សេចក្តីសម្រេចនោះគឺថា "ការស៊ើប</u>

២១(៤) រួមទាំងការទន្ទឹងរង់ចាំអស់រយៈពេលជាយូររបស់ជនរងគ្រោះដែលចង់បាននូវការស៊ើបសួរមួយដែលប្រព្រឹត្តទៅនៅក្នុងចិរវេលាមួយសមស្រប សហចៅក្រមស៊ើបអង្កេតបានសម្រេចឯកភាពទទួលយកសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយទុកលទ្ធភាពឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃអំពីចំណាត់ការបន្តនៃនីតិវិធីដែលពាក់ព័ន្ធនឹងបទល្មើសក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ទាំងនោះ"]។

[113] សំណុំរឿង ០០២-**ឯកសារ D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៧៦។

[114] សំណុំរឿង ០០២-**ឯកសារ D427/1/6** បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ កថាខណ្ឌ ១៧៤-១៧៥។

<u>អង្កេតត្រូវតែបន្ត” ស្របទៅនឹងវិធីសាស្ត្រដែលសហចៅក្រមស៊ើបអង្កេតបានយកមកអនុវត្ត នៅក្នុងករណីបច្ចុប្បន្ន</u>[115]។

38. នៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ មាស មុត ព្យាយាមបញ្ចុះបញ្ចូល អ.ប.ជ ឱ្យអនុវត្តតាមការបកស្រាយមួយដែលផ្ទុយនឹងច្បាប់គ្រប់គ្រង អ.វ.ត.ក និងសាវតារនីតិវិធីរបស់ អ.វ.ត.ក ទាំងស្រុង។ គាត់តវ៉ាថា ការបកស្រាយលើអត្ថបទទាំងឡាយមិនសមហេតុផល ដើម្បីច្រានអត្ថបទទាំងនោះចោល ដោយពុំទទួលយកការបកស្រាយត្រង់ៗលើបទប្បញ្ញត្តិពាក់ព័ន្ធទាំងអស់។ ដំណោះស្រាយសមហេតុផលបំផុតមួយចំពោះការព្រួយបារម្ភរបស់ មាស មុត អំពី “កន្លែងរងទុក្ខជាច្រើនឆ្នាំ” នៃ “ការទុកដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមិនអាចជំទាស់បានឱ្យនៅលងបន្លាចគ្មានទីបញ្ចប់”[116] គឺត្រូវទទួលយកសេចក្តីសម្រេចស្តីពីគោលនយោបាយនៅក្នុងវិធាន ៧៧(១៣) ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង អ.វ.ត.ក ដើម្បីបញ្ជូនរឿងក្តីនេះទៅជំនុំជម្រះ។ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គាត់នឹងទទួលបានសិទ្ធិ ដែលគាត់បានស្នើសុំស្របតាមច្បាប់គ្រប់គ្រង អ.វ.ត.ក និងរដ្ឋធម្មនុញ្ញ ដើម្បីការពារខ្លួនប្រឆាំងបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចជនជាប់ចោទនៅក្នុងសំណុំរឿង ០០១ និង ០០២ ធ្លាប់បានធ្វើ[117]។ ម្យ៉ាងវិញទៀត គាត់នឹងទទួលបានប្រយោជន៍ពីសច្ចធារណ៍និរទោស និងវិធានស្តីពីសម្លេងភាគច្រើនលើសលប់ ដោយសារគាត់អាចត្រូវបានសម្រេចឱ្យមានពិរុទ្ធភាពតែក្នុងករណីចៅក្រមចំនួន ០៤ រូប ក្នុងចំណោម ០៥ រូប នៅអង្គជំនុំជម្រះសាលាដំបូងរកឃើញពិរុទ្ធភាព ហួសពីវិមតិសង្ស័យ[118]។

ii. គោលការណ៍ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ *ពុំតម្រូវថា ដីកាលើកលែងការចោទប្រកាន់មានអានុភាពលប់លើដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ*

---

115 សំណុំរឿង ០០២-**ឯកសារ D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៤ (គូសបញ្ជាក់បន្ថែម)។

116 **ឯកសារ D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣។

117 **ឯកសារ D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣-៤៤។

118 *ផ្ទុយពី* **ឯកសារ D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣-៤៤, ៤៦។ ដូចបានកត់សម្គាល់ខាងលើ អ.ប.ជ បានបញ្ជាក់រួចមកហើយថា ការបញ្ជូនបទចោទណាមួយទៅអង្គជំនុំជម្រះសាលាដំបូង ដែល ស.ច.ស មិនយល់ស្របគ្នា មិនរំលោភបំពានទៅលើការសន្មតជាមុនថាពុំមានទោសរបស់ជនត្រូវចោទនោះទេ៖ សំណុំរឿង ០០២-**ឯកសារ D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៤។

39. មាស មុត តវ៉ាថា បើសិនជាពុំមានសេចក្ដីសម្រេចដោយសម្លេងភាគច្រើនលើសលប់របស់ អ.ប.ជ ច្រានចោលដីកាសម្រេចលើកលែងការចោទប្រកាន់ ដីកានេះត្រូវមានអានុភាពលប់លើដីកាបញ្ជូនរឿងទៅជំនុំជម្រះអនុលោមតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*[119]។ គាត់តវ៉ាថា ទ្រឹស្តី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* មានន័យថា វិមតិសង្ស័យទាំងអស់ ទាំងចំពោះអង្គហេតុ និងបទប្បញ្ញត្តិច្បាប់ទាំងអស់ ត្រូវសម្រេចជាប្រយោជន៍ដល់រូបគាត់[120]។

40. ចំណុចនេះខុសតែម្តងដោយសារហេតុផលមួយចំនួន។ បើទោះ អ.ប.ជ ពុំបានសម្រេចតាមសម្លេងភាគច្រើនលើសលប់ នាំឲ្យច្រានចោលដីកាសម្រេចលើកលែងការចោទប្រកាន់ ដូចបានរៀបរាប់លម្អិតខាងលើក៏ដោយ ក៏បទប្បញ្ញត្តិពាក់ព័ន្ធនៃវិធានផ្ទៃក្នុងច្បាប់ អ.វ.ត.ក កិច្ចព្រមព្រៀង និងយុត្តិសាស្ត្រ អ.ជ.ត.ក និង អ.ប.ជ តម្រូវថា ប្រសិនបើ អ.ប.ជ ខកខានមិនអាចរកសម្លេងតាមច្បាប់តម្រូវដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឬ ប្រសិនបើខ្លួនយល់ថា គ្មាន ស.ច.ស ណាម្នាក់ មានកំហុស រឿងក្តីនោះត្រូវបញ្ជូនទៅជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ[121]។ លទ្ធផលបែបនេះពុំរំលោភគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដោយសារពុំមាន "វិមតិសង្ស័យ" ត្រូវសម្រេចជាប្រយោជន៍នោះទេ នេះជាវិធីដំណើរការនីតិវិធីទៅមុខ ដែលត្រូវបានគាំទ្រដោយប្រភពទាំងអស់នេះ[122]។

41. ទោះក្នុងករណីណាក៏ដោយ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា[123] ហើយអនុលោមតាមក្របខ័ណ្ឌច្បាប់ អ.វ.ត.ក និងច្បាប់

---

119 **ឯកសារ D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១ កថាខណ្ឌ ៦៦។ *សូមមើលផងដែរ* ទំព័រ ២ កថាខណ្ឌ ២, ៤៥, ៤៩, ៥៩, ៦២-៦៦។

120 **ឯកសារ D267/4** បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២ កថាខណ្ឌ ៤, ៤៥, ៤៩-៥១, ៦៥-៦៦។

121 *សូមមើល* **ឯកសារ D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៩១-១៩៨។

122 *សូមមើលខាងលើ* កថាខណ្ឌ ២២-៣៨។

123 រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា ៣៨ ["វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ"]។

អន្តរជាតិ[124] ករណីថាតើបញ្ហាចោទថាត្រូវបញ្ជូនជនត្រូវចោទទៅជំនុំជម្រះដែរឬទេនោះ ពុំជាប់ពាក់ព័ន្ធនៅក្នុងស្ថានភាពនៃភាពពុំច្បាស់លាស់ផ្នែកនីតិវិធីដូចក្នុងករណីនេះឡើយ។ ដូច មាស មុត ទទួលស្គាល់[125] គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* គឺជាលទ្ធផលនៃសច្ចធារណ៍និរទោស ហើយគឺជាទិដ្ឋភាពនៃលក្ខខណ្ឌតម្រូវថា ពិរុទ្ធភាពត្រូវសម្រេចឲ្យហួសវិមតិសង្ស័យនៅពេលជំនុំជម្រះ[126]។ មុខងារចម្បងនៃគោលការណ៍នេះគឺត្រូវសម្រេចលើបញ្ហាអង្គហេតុ និងត្រូវសម្រេចទៅតាមអង្គហេតុក្នុងករណីដែលវិមតិសង្ស័យលើអង្គហេតុពុំត្រូវបានសម្រេច

---

124 **ឯកសារ** D267/4 បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២ កថាខណ្ឌ ៤, ៣២, ៤១, ៤៥-៤៦, ៥០-៥១, ៦៦, ៦៨ និងអត្ថបទដកស្រង់ខាងក្នុង។

125 **ឯកសារ** D267/4 បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៥១។

126 សំណុំរឿង ០០២-**ឯកសារ** E50/3/1/4 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ (“សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែងរបស់ អៀង សារី”) កថាខណ្ឌ ៣១ [“អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់យ៉ាងមុតមាំថា គោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនសង្ស័យ ដែលកើតចេញពីគោលការណ៍ការសន្មតទុកជាមុនថាគ្មានទោស ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា ...”]។ *រឿងក្ដី Limaj និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-03-66-A អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ ២១ [“អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនសង្ស័យ ជាការសន្និដ្ឋានពីការសន្មតទុកជាមុនថាគ្មានទោស និងបន្ទុកបង្ហាញភស្ដុតាងឲ្យហួសពីវិមតិសង្ស័យ អនុវត្តចំពោះសេចក្ដីសន្និដ្ឋាននានាដែលតម្រូវចំពោះការផ្ដន្ទាទោស ដូចជាសេចក្ដីសន្និដ្ឋាននានាដែលបង្កើតជាធាតុផ្សំនៃបទល្មើសដែលត្រូវបានចោទប្រកាន់។ [...] គោលការណ៍នេះមានសារសំខាន់ជាទិដ្ឋភាពមួយនៃលក្ខខណ្ឌតម្រូវដែលត្រូវបង្ហាញនូវពិរុទ្ធភាពឲ្យហួសពីវិសមតិសង្ស័យ”]។ *រឿងក្ដី Renzaho* សំណុំរឿងលេខ ICTR-97-31-A អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៤៧៤ [“គោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនសង្ស័យកំណត់ថា វិមតិសង្ស័យនានាត្រូវដោះស្រាយដោយផ្ដល់ជាប្រយោជន៍ដល់ជនជាប់ចោទ។ អង្គជំនុំជម្រះតុលាការកំពូលរម្លឹកថា ជាការសន្និដ្ឋានពីការសន្មតទុកជាមុនថាគ្មានទោស និងបន្ទុកបង្ហាញភស្ដុតាងឲ្យហួសពីវិមតិសង្ស័យ គោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនសង្ស័យ អនុវត្តចំពោះសេចក្ដីសន្និដ្ឋាននានាដែលតម្រូវចំពោះការផ្ដន្ទាទោស ដូចជាសេចក្ដីសន្និដ្ឋាននានាដែលបង្កើតជាធាតុផ្សំនៃបទល្មើសដែលត្រូវបានចោទប្រកាន់”(លុបអត្ថបទដកស្រង់ខាងក្នុង)]។ *សូមមើលផងដែរ រឿងក្ដី Delalić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-21-T អង្គជំនុំជម្រះសាលាដំបូង សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ (“សាលក្រមសំណុំរឿង *Čelebići*”) កថាខណ្ឌ ៦០១ [“ការចោទប្រកាន់ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការបញ្ជាក់ថា ការចោទប្រកាន់ចំពោះជនជាប់ចោទហួសពីវិមតិសង្ស័យ។ នៅពេលបញ្ចប់រឿងក្ដី ជនជាប់ចោទមានសិទ្ធិទទួលបានផលប្រយោជន៍ពីវិមតិសង្ស័យ ថាតើ បទល្មើសត្រូវបានបញ្ជាក់ ឬយ៉ាងណា”]។

តាមរយៈភ័ស្តុតាងនោះ[127]។ និយាយដោយសាមញ្ញទៅ វាគ្រាន់តែជាវិធាននៃការបង្ហាញភ័ស្តុតាង ពុំមែនជាវិធាននៃការបកស្រាយច្បាប់នោះឡើយ។

42. ទោះបីជានៅក្នុងករណីដ៏កម្រដែលអនុវត្តចំពោះបញ្ហាអង្គច្បាប់ក៏ដោយ ដូចក្នុងករណីគោលការណ៍ពាក់ព័ន្ធនឹងសច្ចធារណ៍និរទោស គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ពាក់ព័ន្ធចម្បងនឹងវិមតិសង្ស័យចំពោះច្បាប់ព្រហ្មទណ្ឌ*សារធាតុ*។ ដូច្នេះ ត្រង់ករណីនេះទេ ពុំមែនបញ្ហានីតិវិធី ដែលកំណត់ពិរុទ្ធភាពចុងក្រោយរបស់ជនជាប់ចោទ[128]។ បញ្ហានៅទីនេះពុំពាក់ព័ន្ធនឹងពិរុទ្ធភាព ឬ ការគ្មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាល់តែសោះ។ ផ្ទុយទៅវិញ វាជាបញ្ហាថាតើគាត់នឹងត្រូវបានជំនុំជម្រះចំពោះបទចោទទាំងនោះដែរឬទេ។ ដូចបានកត់សម្គាល់ ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ រួមទាំង មាស មុត ទទួលបានសច្ចធារណ៍និរទោស លើកលែង ឬ រហូតដល់ពេលមានការសម្រេចពិរុទ្ធភាពតាមសម្លេងភាគច្រើនលើសលប់ដោយចៅក្រមអង្គជំនុំជម្រះសាលាដំបូង។

---

[127] សំណុំរឿង ០០២-**ឯកសារ E50/3/1/4** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែងរបស់ អៀង សារី កថាខណ្ឌ ៣១។ **ឯកសារ D87/2/1.7/1/1/7** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ កថាខណ្ឌ ៦៥។ *រឿងក្តី Stakić* សំណុំរឿងលេខ IT-97-24-T អង្គជំនុំជម្រះសាលាដំបូង សាលក្រម ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៤១៦ [គោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនសង្ស័យ "អនុវត្តចំពោះសេចក្តីសន្និដ្ឋានលើអង្គហេតុ"]។

[128] *សូមមើលឧទាហរណ៍* លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ 2187 UNTS 90 មាត្រា ២២(២) ["និយមន័យនៃបទល្មើសព្រហ្មទណ្ឌត្រូវតែបកស្រាយអធិប្បាយឲ្យល្អិត ហើយមិនត្រូវពង្រីកវិសាលភាព ដោយការប្រៀបធៀប (analogy) ឡើយ។ នៅក្នុងករណីមានវិមតិសង្ស័យ ការកំណត់និយមន័យនោះ ត្រូវបកស្រាយជាប្រយោជន៍ដល់ជនដែលកំពុងត្រូវរកការធ្វើការស៊ើបអង្កេត ត្រូវនាំយកមកជំនុំជម្រះ ឬ ត្រូវបានសម្រេចឲ្យបានពិរុទ្ធភាព"]។ *សូមមើលបន្ថែម រឿងក្តី Gbagbo និង Goudé* សំណុំរឿងលេខ ICC-02/11-01/15-744 អង្គជំនុំជម្រះតុលាការកំពូល សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Laurent Gbagbo និងលោក Charles Blé Goudé ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ មានចំណងជើង "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ចូលសក្ខីកម្មដែលបានកត់ត្រាពីមុនអនុលោមតាមវិធាន ៦៨(២)(ខ) និង ៦៨(៣)" ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៣ ["អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា គោលការណ៍វិមតិសង្ស័យបានជាប្រយោជន៍ ដល់ជនសង្ស័យមានចែងក្នុងមាត្រា ២២(២) នៃលក្ខន្តិកៈ ជាគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌដែលត្រូវយកមកអនុវត្ត នៅពេលមានភាពស្រពិចស្រពិល ក្នុងការបកស្រាយនិយមន័យនៃបទល្មើសណាមួយ"]។

43. ទោះក្នុងករណីណាក៏ដោយ ការអនុវត្តដោយចង្អៀតចំពោះចំណុចស្រពិចស្រពិលនៃច្បាប់គឺកម្រិតត្រឹមវិមតិសង្ស័យដែលនៅកើតមានក្រោយ *ការបកស្រាយ*ដោយប្រើប្រាស់វិធាននៃការបកស្រាយក្រោមច្បាប់ស៊ីវិលឡ គឺ ក្រោយពីពិចារណាលើពាក្យពេចន៍នៃបទប្បញ្ញត្តិ ឋានៈនៅក្នុងប្រព័ន្ធច្បាប់ (រួមទាំង ការពាក់ព័ន្ធនឹងគោលការណ៍ចម្បងៗ) និងគោលបំណងរបស់វា[129]។ រាល់អត្ថបទច្បាប់ត្រូវយកមកបកស្រាយ ហើយករណីថា ស្ថានភាពជាក់លាក់ណាមួយពុំមានចែងច្បាស់លាស់នៅក្នុងអត្ថបទច្បាប់នោះ នឹងលេចឡើងជា "វិមតិសង្ស័យ" ដែលជនជាប់ចោទនឹងតែងតែទទួលបានប្រយោជន៍ជានិច្ច។ ដូច អ.ជ.ត.ក បញ្ជាក់ "គោលការណ៍ *វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនត្រូវចោទ*"[130]។

44. ការសម្រេចនៅក្នុងសំណុំរឿង ០០២ ក៏ផ្ទុយពីការលើកឡើងរបស់ មាស មុត ចំពោះគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*នៅក្នុងរឿងក្តីនេះផងដែរ។ ជនជាប់ចោទនៅក្នុងរឿងក្តីនោះតវ៉ាថា វិធាន ២១(១) តម្រូវឱ្យតុលាការបកស្រាយវិធានផ្ទៃក្នុងជាប្រយោជន៍ដល់ពួកគេ ដើម្បីធានាផលប្រយោជន៍របស់ជនជាប់ចោទ ប៉ុន្តែ អ.ជ.ត.ក បានសម្រេចថា ការណែនាំនៅក្នុងវិធានផ្ទៃក្នុងចំពោះការបកស្រាយ "មិនមានន័យ...ថា វិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទដោយស្វ័យប្រវត្តិនៅក្នុងគ្រប់ស្ថានភាពជាក់លាក់ដែលកើតចេញពីការបកស្រាយនៃវិធានផ្ទៃក្នុងឡើយ" ពោលគឺ ការពិចារណាពាក់ព័ន្ធគឺថា ការបកស្រាយពុំ

---

129 សំណុំរឿង ០០២-**ឯកសារ E50/3/1/4** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែងរបស់ អៀង សារី កថាខណ្ឌ ៣១ [ពន្យល់បន្ថែមថា វិធាននៃការបកស្រាយច្បាប់នៅក្នុងប្រព័ន្ធស៊ីវិលឡពិចារណាលើ "ពាក្យពេចន៍នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុងប្រព័ន្ធ រួមមានការជាប់ទាក់ទិនទៅនឹងគោលការណ៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍នេះ"]។ *សាលក្រមសំណុំរឿង Čelebić* កថាខណ្ឌ ៤១៣ ["ប្រសិទ្ធភាពនៃភាពរិតត្បិតនៃបទប្បញ្ញត្តិនៅក្នុងច្បាប់ព្រហ្មទណ្ឌគឺថា នៅពេលមានពាក្យមិនច្បាស់លាស់ ឬឃ្លាដែលស្រពិចស្រពិលដែលធ្វើឱ្យមានវិមតិសង្ស័យនៃអត្ថន័យរបស់វា *ដែលគោលការណ៍ទូទៅមិនបានដោះស្រាយ* ផលប្រយោជន៍នៃវិមតិសង្ស័យគួរតែផ្តល់ចំពោះបុគ្គល និងប្រឆាំងចំពោះស្ថាប័ននីតិប្បញ្ញត្តិដែលមិនបានពន្យល់ឱ្យច្បាស់។ ហេតុនេះបានជាច្បាប់ព្រហ្មទណ្ឌដែលស្រពិចស្រពិលត្រូវបានបកស្រាយ *ជាប្រយោជន៍ដល់អ្នកដែលច្បាប់ចែងប្រឆាំង (contra proferentem)*" (គូសបញ្ជាក់បន្ថែម)]។

130 សំណុំរឿង ០០២-**ឯកសារ E50/3/1/4** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែងរបស់ អៀង សារី កថាខណ្ឌ ៣១។ **ឯកសារ D261** ដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ២។

រំលោភលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទនោះទេ[131]។ ជាការពិតណាស់ នៅពេលអានរួមគ្នាទាំងមូល វិធាន ២១ តម្រូវឱ្យបកស្រាយច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធានាជានិច្ចដល់ផលប្រយោជន៍មិនមែនសម្រាប់តែជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទនោះទេ ហើយក៏សម្រាប់*ជនរងគ្រោះ*ផងដែរ។ អ.ប.ជ ធ្លាប់បានសម្រេចនាពេលមុនរួចហើយថា វិធានផ្ទៃក្នុងត្រូវបកស្រាយក្នុងលក្ខណៈមួយដោយត្រូវពិចារណាអំពីតម្រូវការរបស់សហគមន៍ដែលរងការប៉ះពាល់ដូចមានចែងច្បាស់នៅក្នុងលិខិតុបករណ៍បង្កើត អ.វ.ត.ក ផងដែរ[132]។

45. ចំណុចនេះស្របគ្នាទាំងស្រុងជាមួយនឹងវិធាន ២ ដែលចែងថា៖

> នៅក្នុងអំឡុងពេលដំណើរការរបស់អង្គជំនុំជម្រះ ប្រសិនបើមានបញ្ហាណាមួយកើតមានឡើង ដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្ត ដោយស្របទៅលើមាត្រា ១២(១) នៃកិច្ចព្រមព្រៀង និងមាត្រា ២០ថ្មី ២៣ថ្មី ៣៣ថ្មី ឬ មាត្រា ៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើ**គោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ** និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន[133]។

---

[131] *សូមមើលឧទាហរណ៍* សំណុំរឿង ០០២-**ឯកសារ E50/2/1/4** សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣៩។ សំណុំរឿង ០០២-**ឯកសារ E50/3/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣០ (*សូមមើលផងដែរ* កថាខណ្ឌ ៣១)។ សំណុំរឿង ០០២-**ឯកសារ E154/1/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង*របស់មន្ត្រីច្បាប់ជាន់ខ្ពស់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ១៤។

[132] សំណុំរឿង ០០២-**ឯកសារ D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៧។

[133] គូសបញ្ជាក់បន្ថែម។

និយាយឲ្យខ្លីទៅ វិធាននេះចែងថា ក្នុងករណីសេណារីយ៉ូជាក់លាក់មួយពុំលើកឡើងនៅក្នុងវិធានផ្ទៃក្នុងទេនោះ ស្ថាប័នធ្វើសេចក្តីសម្រេច*ត្រូវ*បកស្រាយបទប្បញ្ញត្តិដោយគោរពច្បាប់កម្ពុជា និងវិធាននីតិវិធីអន្តរជាតិពាក់ព័ន្ធ ហើយដោយគោរពសិទ្ធិរបស់គ្រប់ភាគី*ទាំងអស់*។ គ្មានចំណុចត្រង់ណាមួយចែងអំពីការសម្រេចដោយស្វ័យប្រវត្តិទាំងនោះជាប្រយោជន៍ដល់ជនសង្ស័យ ជនត្រូវចោទ ឬ ជនជាប់ចោទនោះទេ។

46. វាជាគោលការណ៍មូលដ្ឋាននៃច្បាប់នៅ អ.វ.ត.ក[134] និងសាលាក្តីអន្តរជាតិ[135] ព្រមទាំងនីតិវិធីច្បាប់កម្ពុជា និងបារាំង[136] ដែលថា អនុលោមតាមគោលការណ៍នីត្យានុកូលភាព សិទ្ធិជំនុំជម្រះក្តីដោយ

---

[134] វិធាន ២១(១) នៃវិធានផ្ទៃក្នុង [គោលការណ៍ជាសារវន្តគ្រប់គ្រងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក បង្គាប់ថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍ [...] ជនរងគ្រោះ [...] ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ [...] អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី"]។ *សូមមើលបន្ថែម* **ឯកសារ D269/3.1.1** មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីប្រកាសស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ នៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច UNGA Res 40/34 ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ គោលការណ៍ទី ៤ ["ជនរងគ្រោះត្រូវទទួលការប្រព្រឹត្តដោយក្តីមេត្តា និងគោរពដល់សេចក្តីថ្លៃថ្នូររបស់ពួកគេ។ ពួកគេមានសិទ្ធិទទួលបានយន្តការយុត្តិការ និងដំណោះស្រាយទាន់ពេលវេលា ដូចមានចែងក្នុងនីតិកម្មថ្នាក់ជាតិ ចំពោះព្យសនកម្មដែលពួកគេបានទទួលរង"]។

[135] *រឿងក្តី Aleksovski* សំណុំរឿងលេខ IT-95-14/1 អង្គជំនុំជម្រះតុលាការកំពូល សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាស្តីពីភាពទទួលយកបាននៃភស្តុតាង ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ កថាខណ្ឌ ២៥ ["ការអនុវត្តទស្សនៈនៃការជំនុំជម្រះដោយយុត្តិធម៌ជាប្រយោជន៍ដល់ភាគីទាំងពីរអាចទទួលយកបាន ដោយសារអយ្យការដើរតួនាទីក្នុងនាម និងជាប្រយោជន៍របស់សហគមន៍ រួមមាន ផលប្រយោជន៍របស់ជនរងគ្រោះនៃបទល្មើសដែលបានចោទប្រកាន់ (ក្នុងករណី នៅចំពោះមុខសាលាជម្រះក្តី រដ្ឋអាជ្ញាដើរតួនាទីក្នុងនាមសហគមន៍អន្តរជាតិ)។ គោលការណ៍សមភាពនេះមិនប៉ះពាល់ដល់ការការពារជាសារវន្តដែលមានចែងក្នុងច្បាប់ទូទៅ ឬលក្ខន្តិកៈចំពោះជនជាប់ចោទ និងដំណើរការជំនុំជម្រះទល់នឹងសារតារនៃការការពារជាសារវន្ត។ នៅក្នុងវិធីនេះ ជាការលំបាកក្នុងការរករបៀបដែលការជំនុំជម្រះអាចត្រូវបានចាត់ទុកថាមានភាពយុត្តិធម៌ ដែលជនជាប់ចោទបានទទួលប្រយោជន៍ ដោយប៉ះពាល់ដល់អយ្យការ ហួសពីភាពសមស្របយ៉ាងតឹងរ៉ឹងទៅនឹងការការពារជាសារវន្តទាំងនោះ"]។ *សូមមើលផងដែរ រឿងក្តី Zigiranyirazo* សំណុំរឿងលេខ ICTR-2001-73-T សេចក្តីសម្រេចទៅលើញត្តិរួមគ្នារបស់អយ្យការដែលស្នើសុំបើករឿងក្តីរបស់ខ្លួនឡើងវិញ និងសុំសេចក្តីពិចារណាសាជាថ្មីទៅលើសេចក្តីសម្រេចចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ ស្តីពីការស្តាប់សក្ខីកម្មរបស់សាក្សី Michel Bagaragaza តាមរយៈប្រព័ន្ធសោតទស្សន៍ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១៨ ["ការការពារសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីសំដៅដល់ការរក្សានូវភាពយុត្តិធម៌ក្នុងដំណើរការសំណុំរឿង ពាក់ព័ន្ធនឹងភាគី*ទាំងពីរ*"]។ *រឿងក្តី*

Karemera និងអ្នកផ្សេងទៀត សំណុំរឿងលេខ ICTR-98-44-PT សេចក្តីសម្រេចលើការបំបែកសំណុំរឿងរបស់ André Rwamakuba និងការកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ២៦ [“ចុងក្រោយ អង្គជំនុំជម្រះដឹងពីកាលៈទេសៈពិសេសនៃរឿងក្តី និងផលវិបាកនៃកាលៈទេសៈទាំងនោះទៅលើការចោទប្រកាន់។ អង្គជំនុំជម្រះរម្លឹកថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អនុវត្តចំពោះផ្នែកការពារក្តីផង និងផ្នែកចោទប្រកាន់ផង។ អង្គជំនុំជម្រះត្រូវធានាគោរពដល់ផលប្រយោជន៍យុត្តិធម៌”]។ *រឿងក្តី ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ* សំណុំរឿងលេខ ICC-01/04 សេចក្តីសម្រេចលើពាក្យសុំរបស់អយ្យការ ដែលស្នើសុំការអនុញ្ញាតប្តឹងសាទុក្ខទៅលើសេចក្តីសម្រេចចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ របស់អង្គជំនុំជម្រះ ស្តីពីពាក្យសុំចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ VPRS 1, VPRS 2, VPRS 3, VPRS 4, VPRS 5 និង VPRS 6 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ៣៨ [“ពាក្យថា “ភាពយុត្តិធម៌” (“fairness” (*equité*)) មកពីភាសាឡាតាំង “*equus*” មានន័យថា លំនឹង ឬតុល្យភាព។ ជាទស្សនៈគតិយុត្តិ សមធម៌ ឬ ភាពយុត្តិធម៌ “គឺជាការបញ្ចេញមតិដោយផ្ទាល់ពីគំនិតនៃយុត្តិធម៌”។ សមធម៌នៃកិច្ចដំណើរការនីតិវិធីតម្រូវឱ្យមានលំនឹងរវាងភាគីទាំងពីរ ដែលសន្មតពីការគោរពដល់គោលការណ៍សមភាពផង និងគោលការណ៍នៃកិច្ចដំណើរការនីតិវិធីតទល់គ្នាផង។ អង្គជំនុំជម្រះយល់ឃើញថា ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីរួមមាន ការគោរពសិទ្ធិរបស់រដ្ឋអាជ្ញា ផ្នែកការពារក្តី និងជនរងគ្រោះទៅតាមនីតិវិធី ដែលត្រូវបានធានាដល់ច្បាប់ពាក់ព័ន្ធ (នៅក្នុងប្រព័ន្ធនានាដែលផ្តល់ឱ្យជនរងគ្រោះអាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ)”]។ *រឿងក្តី ស្ថានភាពនៅប្រទេសអ៊ូហ្កង់ដា* សេចក្តីសម្រេចទៅលើពាក្យសុំរបស់អយ្យការដែលស្នើសុំការអនុញ្ញាតប្តឹងសាទុក្ខទៅលើសេចក្តីសម្រេចលើពាក្យសុំចូលរួមរបស់ជនរងគ្រោះ a/0010/06, a/0064/06 ដល់ a/0070/06, a/0081/06 ដល់ a/0104/06 និង a/0111/06 to a/0127/06 សំណុំរឿងលេខ ICC-02/04-01/05 ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ ២៧ [“មានការយល់ដឹងជាទូទៅថា សិទ្ធិទទួលបានកិច្ចដំណើការនីតិវិធីជំនុំជម្រះដោយយុត្តិធម៌ធានាជាចម្បងនូវគុណប្រយោជន៍របស់ចុងចោទ ឬផ្នែកការពារក្តី។ ប៉ុន្តែ ភាពយុត្តិធម៌ក៏ទៅដល់ភាគីផ្សេងទៀតនៅក្នុងកិច្ចដំណើរការនីតិវិធីផងដែរ ដូចជាផ្នែកចោទប្រកាន់ជាដើម”]។

136 <u>បារាំង៖</u> ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង (“FCCP”), Article préliminaire [“La procédure pénale doit être équitable et contradictoire et préserver l’équilibre des droits des parties. […] L’authorité judiciaire veille […] à la garantie des droits des victimes au cours de toute procédure pénale.”។ បកប្រែក្រៅផ្លូវការ៖ “កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវតែមានសមធម៌ និងមានភាពតទល់នឹង និង រក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគី។ […] អាជ្ញាធរតុលាការត្រូវធានាសិទ្ធិរបស់ជនរងគ្រោះក្នុងអំឡុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងមូល”]។ ក្រុមប្រឹក្សាធម្មនុញ្ញ (បារាំង) លេខ ៩៥-៣៦០ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩៥ កថាខណ្ឌ ៥ [“Considérant […] que le principe du respect des droits de la défense constitue un des principes fondamentaux reconnus par les lois de la République […]; qu’il implique, notamment en matière pénale, l’existence d’une procédure juste et équitable garantissant l’équilibre des droits des parties”។ បកប្រែក្រៅផ្លូវការ៖ “ដោយពិចារណា […] ថា គោលការណ៍គោរពសិទ្ធិនៃការការពារក្តី បង្កើតជាគោលការណ៍ជាសារវ័ន្តមួយក្នុងចំណោមគោលការណ៍ជាសារវ័ន្តនានាដែលច្បាប់ [បារាំង] បានទទួលស្គាល់ ថា នៅក្នុងបញ្ហាព្រហ្មទណ្ឌ វាសំដៅដល់អត្ថិភាពនៃនីតិវិធីយុត្តិធម៌ និងសមធម៌ដែលធានាឱ្យមានតុល្យភាពរវាងសិទ្ធិរបស់ភាគី”]។ *សូមមើលផងដែរ* Pradel, *Manuel de Procédure Pénale* (ការកែសម្រួលទី ១៤) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨ ទំព័រ ១៤១ [“le parquet est une partie originale à ce procès, une partie différente des autres, car il défend les intérêts de la société.”។ បកប្រែក្រៅផ្លូវការ៖ “រដ្ឋ

យុត្តិធម៌ ពុំមែនជាសិទ្ធិតែមួយគត់សម្រាប់ជនជាប់ចោទ ប៉ុន្តែ វាក៏ជាសិទ្ធិរបស់ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីផងដែរ រួមទាំង ជនរងគ្រោះ និងស្ថាប័នអយ្យការ ដែលធ្វើបណ្តឹងតំណាងជនរងគ្រោះ និងតំណាងផលប្រយោជន៍របស់សង្គមកម្ពុជា និងមនុស្សជាតិទាំងអស់។

47. ការលើកលែងការចោទប្រកាន់នៅក្នុងសំណុំរឿង ០០៣ ដោយពុំមានការជំនុំជម្រះលើអង្គសេចក្តី នឹងជាការខកខានមិនបានផ្តល់វិធានការយុត្តិធម៌ដល់ជនរងគ្រោះរាប់ម៉ឺននាក់ ដែលបានរង់ចាំឲ្យមានការទទួលខុសត្រូវនេះរយៈពេល ០៤ ទសវត្សរ៍មកហើយ។ ការលើកលែងការចោទប្រកាន់ក៏ជាការរំលោភលើសិទ្ធិជាក់លាក់ ដែលផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្របខ័ណ្ឌ អ.វ.ត.ក ផងដែរ។ ប្រសិនបើសំណុំរឿង ០០៣ បញ្ជូនទៅជំនុំជម្រះ អ្នកដែលត្រូវបានជ្រើសរើសជាដើមបណ្តឹងរដ្ឋប្បវេណី នឹងមានសិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី អាចរៀបរាប់រឿងរ៉ាវរបស់ខ្លួនឲ្យគេស្តាប់ និងស្នើសុំសំណង[137]។ ការបញ្ចប់កិច្ចដំណើរការនីតិវិធីនៅពេលដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពមួយ គឺជាការបំពានលើសិទ្ធិទាំងនេះ ហើយនិយាយឲ្យទូលាយជាងនេះ គឺជាការមើលងាយដល់បុរស និងស្ត្រីជាច្រើន ដែលបានមកជួយជ្រោមជ្រែងដល់តុលាការតាមរយៈការផ្តល់ភ័ស្តុតាងជូន ស.ច.ស។

48. កិច្ចព្រមព្រៀង អ.វ.ត.ក ចែងនៅក្នុងបុព្វកថា ថា "ដោយហេតុថា [សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ [លេខ ៥៧/២២៨] បានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជា *ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ* ស្ថេរភាព សន្តិភាព និងសន្តិសុខ"[138]។ ចំណុចនេះតម្រូវឲ្យចៅក្រម និងអង្គជំនុំជម្រះនៃ អ.វ.ត.ក ពុំមែនស្វែងរកការពិតអំពីអ្វីដែលបានកើតឡើងនៅកម្ពុជាប៉ុណ្ណោះទេ[139] ហើយក៏ដើម្បីធានាការចូល

អាជ្ញាជាភាគីដើមក្នុងការចាប់ផ្តើមដំណើរការនេះ ជាភាគីដែលខុសពីភាគីផ្សេងទៀត ដោយសារគាត់ការពារប្រយោជន៍សង្គម"]។ <u>កម្ពុជា</u>៖ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CCCP") មាត្រា ៤ ["បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ"]។

137 វិធាន ២៣(១), ៨០(២) នៃវិធានផ្ទៃក្នុង។

138 គូសបញ្ជាក់បន្ថែម។

139 *សូមមើលឧទាហរណ៍* វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង ["ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់"] វិធាន ៨៧(៤) ["អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត"]។ សំណុំរឿង ០០២-**ឯកសារ D164/3/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច

រួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តជាផ្នែកមួយនៃការស្វែងរកការផ្សះផ្សាជាតិផងដែរ[140]។ អ.ប.ជ ធ្លាប់បានសម្រេចពីមុនថា "ការបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងដំណើរការនីតិវិធីគឺជាការទទួលស្គាល់ការបន្តការបង្រួបបង្រួមជាតិ"[141]។

49. ការការពារសិទ្ធិរបស់ជនត្រូវចោទត្រូវបកស្រាយ និងថ្លឹងថ្លែងស្របតាមគោលបំណងជាមូលដ្ឋានរបស់សាលាក្តី "ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណុចនេះរួម

លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ("សេចក្តីសម្រេចអំពីឃ្លាំងផ្ទុកឯកសាររួម") កថាខណ្ឌ ៣៥ ["ដំបូង [ស.ច.ស] ត្រូវតែបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន ដែលមានន័យថា សហចៅក្រមស៊ើបអង្កេតបានបញ្ចប់រាល់កិច្ចស៊ើបសួរទាំងអស់ ដែលខ្លួនចាត់ទុកថាចាំបាច់ ដើម្បីបង្ហាញការពិតទាក់ទងទៅនឹងអង្គហេតុដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែម"]។ **ឯកសារ D120/3/1/8** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញ លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ៣៦ (នៅទំព័រ ៤៨-៤៩) (ចៅក្រម Beauvallet និងចៅក្រម Baik) [បញ្ជាក់ថា "*ភាពចាំបាច់ក្នុងការបញ្ជាក់នូវការពិតអំពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ*"]។ Cass. Crim. ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៦៦ No. 66-90.134 ["alors que la juridiction de renvoi est sur le point d'être saisie et que l'interêt de la manifestation de la verité continue, jusqu'au jugement à intervenir"។ បកប្រែក្រៅផ្លូវការ៖ "ទោះបីតុលាការនឹងទទួលយកសំណុំរឿងយកមកពិនិត្យក៏ដោយ តែផលប្រយោជន៍ក្នុងការបញ្ជាក់ការពិតនៅតែបន្តរហូតដល់ពេលចេញសាលក្រម"]។ Cass. Crim, No. 78-92.277 ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧៩ ["Attendu [...] qu'il appartient aux juges correctionnels d'ordonner les mesures d'information qu'ils constatent avoir été omises et qu'ils déclarent utiles à la manifestation de la vérité"។ បកប្រែក្រៅផ្លូវការ៖ "ចំណែកឯចៅក្រមជំនុំជម្រះគួរចេញបញ្ជាចាត់វិធានការស៊ើបអង្កេតដែលពួកគេរកឃើញថាត្រូវបានគេលុបចោល និងគួរសម្រេចថា ជាប្រយោជន៍សម្រាប់ការបញ្ជាក់ការពិត"]។ *សូមមើលផងដែរ រឿងក្តី Karadžić និង Mladić* សំណុំរឿង IT-95-5-R61 និងសំណុំរឿង IT-95-18-R61 ការពិនិត្យឡើងវិញទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៦១ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៦ កថាខណ្ឌ ៣ ["តុលាការយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ [...] ត្រូវបំពេញទៅតាមបេសកកម្មរបស់ខ្លួនក្នុងការបង្ហាញការពិតពីអំពើនានាដែលបានប្រព្រឹត្ត និងការឈឺចាប់ដែលបានទទួលរង ព្រមទាំងការកំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនជាប់ចោទដែលទទួលខុសត្រូវ"]។

[140] សំណុំរឿង ០០២-**ឯកសារ D411/3/6** សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៤-៦៥។

[141] សំណុំរឿង ០០២-**ឯកសារ C11/53** សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ កថាខណ្ឌ ៣៧។

ទាំងការថ្លឹងថ្លែងសិទ្ធិរបស់ជនត្រូវចោទជាមួយនឹងតម្រូវការក្នុងការបញ្ជាក់ការពិតអំពីឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅក្នុងពេលនៃកិច្ចដំណើរការតុលាការទាំងមូលផងដែរ[142] ព្រមទាំងជាមួយនឹងគោលការណ៍ទូទៅនៃដំណើរការស្វែងរកយុត្តិធម៌ឲ្យបានសមស្របផងដែរ[143]។ ការផ្អាកដំណើរការលើជនជាប់ចោទដោយបញ្ហានីតិវិធី តាមរបៀបនេះរហូតនោះ គឺជាផលប៉ះពាល់គួរឲ្យព្រួយបារម្ភលើដំណើរការនៃការស្វែងរកយុត្តិធម៌តែម្តង។

50. តាមការពិត ដូច អ.ប.ជ ធ្លាប់បានសម្រេចជាឯកច្ឆ័ន្ទពីមុនរួចហើយ ស.ច.ស និង អ.ប.ជ មានកាតព្វកិច្ចលើកស្ទួយ "*ភាពចាំបាច់ជារួម ដើម្បីឲ្យការស៊ើបអង្កេត និងដំណើរការតុលាការបន្តទៅមុខ*"[144]។ ប្រសិនបើភាពមិនប្រាកដប្រជានៃនីតិវិធីអនុញ្ញាតឲ្យផលប្រយោជន៍ដោយស្វ័យប្រវត្តិដល់ជនត្រូវចោទរហូតអាចបញ្ចប់កិច្ចដំណើរការនីតិវិធីនោះ ចំណុចនេះនឹងជាការរំលោភច្បាប់នីតិវិធីកម្ពុជា (និងបារាំង)។ នៅក្នុងនីតិវិធីកម្ពុជា មូលហេតុដែលនាំឲ្យបញ្ចប់បណ្តឹងព្រហ្មទណ្ឌ មានចែងជាក់លាក់នក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយកម្រិតត្រឹមមរណភាពជាប់ចោទ ការផុតរលត់នៃអាជ្ញាយុកាល ការលើកលែងទោស និងនិរាករណ៍នៃច្បាប់ និង*អាជ្ញា*

---

142 *សូមមើលខាងលើ* កថាខណ្ឌ ៤៨។

143 *រឿងក្តី* Boddaert *ទល់នឹង ប្រទេសប៊ែលហ្សិក* No. 12919/87 សាលក្រម ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩២ កថាខណ្ឌ ៣៩ ["មាត្រា ៦ បង្គាប់ថា កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការត្រូវឆាប់រហ័ស តែវាក៏ចែងផងដែរនូវគោលការណ៍កាន់តែទូទៅនៃកិច្ចការរដ្ឋបាលតុលាការឲ្យបានសមស្រប។ នៅក្នុងកាលៈទេសៈនានានៃសំណុំរឿង ការប្រព្រឹត្តិរបស់អាជ្ញាធរស្របទៅនឹងតុល្យភាពដោយយុត្តិធម៌រវាងទិដ្ឋភាពនានានៃលក្ខខណ្ឌជាសារវ័ន្តនោះ"]។ *រឿងក្តី* Neumeister *ទល់នឹង ប្រទេសអូទ្រីស្ត* No. 1936/63 សាលក្រម ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៦៨ កថាខណ្ឌ ២១។ *សូមមើលផងដែរ* សំណុំរឿង ០០២-**ឯកសារ E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ ៧៤ ["បញ្ញត្តិទាំងនេះដែលកំណត់ពីតួនាទីរបស់ចៅក្រមនៅ អ.វ.ត.ក ត្រូវបានបកស្រាយក្នុងន័យធានានូវកិច្ចការរដ្ឋបាលដ៏ល្អប្រសើរបំផុត"]។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២ ["បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះតាមច្បាប់កំណត់"]។

144 សំណុំរឿង ០០២-**ឯកសារ D314/1/8** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៧០។ សំណុំរឿង ០០២-**ឯកសារ D375/1/8** សាលដីកាលើបណ្តឹងឧទ្ធរណ៍ និងសេចក្តីសន្និដ្ឋានបន្ថែមជំទាស់នឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើសំណើរបស់ នួន ជា ឲ្យស្តាប់ចម្លើយសាក្សីមួយចំនួន (D318, D319, D320, D336, D338, D339 & D340) ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១០២។

អស់ជំនុំ[145]។ យុត្តិសាស្ត្រនៅកម្រិតអន្តរជាតិ[146] ក៏ចែងអំពីលក្ខខណ្ឌអប្បបរមាតឹងរ៉ឹងចំពោះការរំលត់ ឬការផ្អាកកិច្ចដំណើរការនីតិវិធី[147]។ អ.ជ.ត.ក និងអង្គជំនុំជម្រះសាលាដំបូង ធ្លាប់បានសម្រេចថា ខ្លួនអនុវត្តតាមលក្ខខណ្ឌថា អ.វ.ត.ក គ្មានសិទ្ធិអំណាចបង្គាប់ឲ្យរំលត់នីតិវិធីដោយសារហេតុផលនានា[148]។ ជាក់ស្តែង អនុលោមតាមវិធាន ៦៧(៣) គ្មានបទប្បញ្ញត្តិណាមួយចែងអំពីការលើកលែងការចោទប្រកាន់លើរឿងក្តីនៅដំណាក់កាលនៃដីកាដំណោះស្រាយ យោងតាមការពិចារណាលើនីតិវិធីនោះឡើយ។ ទោះក្នុងករណីណាក៏ដោយ ការលើកលែងការចោទ

---

145 <u>កម្ពុជា</u>៖ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៧ ចំណងជើង "ការរលត់នៃបណ្តឹងអាជ្ញា" ["មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ ១-មរណភាពនៃជនល្មើស ២-ការផុតអាជ្ញាយុកាល ៣-ការលើកលែងទោសជាទូទៅ ៤-និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ៥-អាជ្ញាអស់ជំនុំ។ កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់"]។ *សូមមើលបន្ថែម* ទាក់ទិននឹងច្បាប់នីតិវិធី<u>បារាំង</u> មាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំងថា៖ ["L'action publique pour l'application de la peine s'éteint par la mort du prévenu, la prescription, l'amnistie, l'abrogation de la loi pénale et la chose jugée."។ បកប្រែក្រៅផ្លូវការ៖ "កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវបានបញ្ចប់ដោយសារចុងចម្លើយបានទទួលមរណភាព ផុតអាជ្ញាយុកាល ការលើកលែងទោស និរាករណ៍ច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ"]។

146 ច្បាប់ អ.វ.ត.ក មាត្រា ៣៣*ថ្មី*។

147 យូរៗម្តង ការបញ្ឈប់ ឬការផ្អាកកិច្ចដំណើរការនីតិវិធីត្រូវបានផ្តល់ដោយសាលាក្តីអន្តរជាតិផ្សេងទៀត តែមានឧទាហរណ៍តិចតួច និងឆ្លុះបញ្ចាំងពីស្ថានភាពដែលការមិនបន្តត្រូវបានយកមកពិចារណាជាការដោះស្រាយ*តែមួយ*ដែលអាចជួយធានានូវភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬជាការចាំបាច់នៃប្រយោជន៍យុត្តិធម៌តាមវិធីផ្សេងទៀត។ *សូមមើលឧទាហរណ៍ រឿងក្តី Karadžić* សំណុំរឿងលេខ IT-95-5/18-T អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើញត្តិស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១០ កថាខណ្ឌ ៤ [ទទួលស្គាល់ថា ការដោះស្រាយជាសំខាន់នៃការផ្អាកកិច្ចដំណើរការនីតិវិធី អាចត្រូវបានផ្តល់ នៅពេលដែលការរំលោភបំពានធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សរបស់ជនជាប់ចោទ ពុំអាចឲ្យការជំនុំជម្រះដោយយុត្តិធម៌បាន]។ *រឿងក្តី Lubanga* សំណុំរឿងលេខ ICC-01/04-01/06-772 អង្គជំនុំជម្រះតុលាការកំពូល សាលដីកាលើបណ្តឹងសាទុក្ខរបស់ Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចរបស់មេធាវីការពារក្តីដែលជំទាស់ទៅនឹងយុត្តាធិការរបស់តុលាការ អនុលោមតាមមាត្រា ១៩(២)(ក) នៃលក្ខន្តិកៈថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០។

148 សំណុំរឿង ០០២-**ឯកសារ E138/1/10/1/5/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៣៨។ សំណុំរឿង ០០២-**ឯកសារ E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (E51/3, E82, E88 និង E92) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៦-១៧ [សន្និដ្ឋានថា កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក អាចត្រូវបានបញ្ចប់តែអនុលោមតាមវិធាន ៨៩(១)(ខ) នៃ វិធានផ្ទៃក្នុង ទៅលើមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានតិចតួចដែលមានកំណត់នៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា]។

ប្រកាន់ដែលពុំពាក់ព័ន្ធនឹងអង្គសេចក្តីនៃរឿងក្តីប្រឆាំងនឹងគាត់ពុំបានការពារកេរ្តិ៍ឈ្មោះ មាស មុត ឬ អនុញ្ញាតឲ្យគាត់មានឱកាសដែលគាត់អះអាងឡើងដើម្បី “តវ៉ាជំទាស់នឹងភ័ស្តុតាងប្រឆាំងនឹងគាត់ តទល់ជាមួយអ្នកចោទប្រកាន់គាត់ ឬ រក្សានិរទោសរបស់គាត់” ក្រោយពេលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ[149]។

IV. ដំណោះស្រាយដែលស្នើសុំ

51. ផ្អែកលើហេតុផលដែលបានបង្ហាញខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិសូមគោរពស្នើសុំឲ្យ អ.ប.ជ ច្រានចោលបណ្តឹងឧទ្ធរណ៍របស់ មាស មុត ហើយបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ៕

កាលបរិច្ឆេទ	**ឈ្មោះ**	**ទីកន្លែង**	**ហត្ថលេខា**
ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩	លោក Nicholas KOUMJIAN សហព្រះរាជអាជ្ញាអន្តរជាតិ	ភ្នំពេញ	

149 **ឯកសារ** D267/4 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៥។